ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 17-Mar-2016, 16:00
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្ដីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៦**

**ម៉ោង ០៩:០៣នាទី**

**សវនាការលើកទី៣៧៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន  ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្ដារា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ម៉ាធូរ ម៉ាកាធី *(Mr.Matthew Mccarthy)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

កញ្ញា សុង ឆវ័ន្ត

លោក ត្រាវីស ហ្វារ *(Mr. Travis FARR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ហុង គឹមសួន

លោក វ៉េន ពៅ

លោកស្រី ជេត វណ្ណលី

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណា

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក ត្រាវីស ហ្វារ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក លីវ សុវណ្ណា | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោកស្រី មឿង ចាន់ឌី (2-TCW-867) | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោកស្រី មឿង ចាន់ឌី** (2-TCW-867)

សួរបន្តដោយលោក លីវ សុវណ្ណា ផ្ដើមពី ................................................................ ទំព័រ ៣
សួរដោយលោក គង់ សំអុន ផ្ដើមពី ................................................................ ទំព័រ ៦

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:៣៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី មឿង ចាន់ឌី ពាក់ព័ន្ធជាមួយនឹងអង្គហេតុមន្ទីរសន្តិសុខអូរកន្សែងបញ្ចប់។

ក្រឡាបញ្ជីសវនាការលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នេះរឿងក្តីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយសាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះ គឺលោកស្រី មឿង ចាន់ឌី។ លោកស្រីនិងបុគ្គលិកអង្គការធី.ភី.អូ លោកស្រី សុន ស្វលីដា មានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ ហើយនៅថ្ងៃនេះផងដែរមិនមានសាក្សីបម្រុងនោះទេ។ សូមអរគុណលោកប្រធាន។

[០៩:០៥:០៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សែ កុលវុឌ្ឍី។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះ

បង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ នៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៦។ មេធាវីការពារក្ដីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថាការលះបង់សិទ្ធិនេះមិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភ័ស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យ ព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថា មានអាការៈឈឺចង្កេះជាប្រចាំ វិលមុខ អង្គុយយូរមិនបាន និងផ្ដល់អនុសាសន៍ថា សុំឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតនៅក្រោមសាលសវនាការនេះ។

[០៩:០៦:២៥]

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាកាសម្រាប់ថ្ងៃនេះ។

ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី មឿង ចាន់ឌី។

**លោក លីវ សុវណ្ណា៖**

សូមគោរពលោកប្រធាន ខ្ញុំបាទបានជជែកជាមួយខាងក្រុមលោក ខៀវ សំផន គឺខ្ញុំសូមម៉ោងគាត់ពី១០ ទៅ១៥នាទី ដើម្បីសួរបញ្ចប់សំណួរខ្ញុំបាទ។

**ប្រធានអង្គជំនុំ៖**

ម៉េចទៅលោក ក្រុមសហមេធាវីការពារក្ដី ខៀវ សំផន មិនអាចលើសពីមួយវគ្គសវនាការនេះបានទេ ពេលវេលាដែលបានបែងចែកឲ្យ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

**លោក គង់ សំអុន៖**

បាទ មិនអីទេ លោកប្រធាន ដោយសារពេល ខាងក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ក៏អត់មានសំណួរច្រើនដែរ បាទ។ សូមអរគុណ។

[០៩:០៧:៣៩]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក នួន ជា!

**លោក លីវ សុវណ្ណា៖**

ជាបឋម ខ្ញុំបាទសូមគោរពលោកប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ។ សូមគោរពភាគីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយលោក លីវ សុវណ្ណា៖**

**ស៖** សូមជម្រាបសួរសាជាថ្មី លោកស្រីសាក្សី។ ខ្ញុំបាទឈ្មោះ លីវ សុវណ្ណា ជាមេធាវីជាតិនៅក្នុងក្រុមការពារក្តីលោក នួន ជា ខ្ញុំបាទសូមបន្តសំណួរមួយចំនួនចំពោះសាកសួរលោកស្រីបន្ថែម។ លោកស្រីសាក្សី ការរស់នៅ ការធ្វើការរបស់លោកស្រីដែលចេញចូលនៅរោងបាយហ្នឹង ការទៅទទួលទានបាយរាល់ពេល ហើយក៏ដូចជាការទៅបេះបន្លែ បេះអីដើម្បីផ្គត់ផ្គង់រោងបាយ តើលោកស្រីដែលប្រទះឃើញមានគេយកប្រមាត់ទៅចងនៅរោងបាយហ្នឹងទេ?

**លោកស្រី មឿង ចាន់ឌី៖**

**ឆ៖** ឃើញប្រមាត់ចងរោងបាយអី គឺអត់ដែលដឹងទេ អត់ដែលឃើញទេ ប៉ុន្តែគ្រាន់តែថាដែលឮតែ តាអ៊ួយ នោះគាត់ថាគាត់ធ្លាប់ធឹកប្រមាត់មនុស្ស។ តែប៉ុណ្ណឹង។

[០៩:០៩:០០]

**ស៖** ចុះលោកស្រីដែលឮថា មានអ្នកណាមួយយកប្រមាត់ទៅចងនៅរោងបាយដែរឬទេ?

**ឆ៖** ចាស អត់ឃើញមានផង។

**ស៖** តើលោកស្រីដែលឮមានអ្នកទោសណាមួយ អ្នកទោសនារីណាមួយដែលឃុំខ្លួនជាមួយលោកស្រី ហើយត្រូវបានចាប់ដោយសារកំហុសខុសសីលធម៌ដែរទេ?

**ឆ៖** ចាស អត់ដឹងផង។ ប៉ុន្តែដឹងថានៅជាមួយខ្ញុំ ប៉ុន្តែមិនដឹងជាខុសរឿងអីៗ អត់ដឹង។ ដឹង

ខុសរឿងអីម៉្យាងៗ គឺខ្ញុំអត់បានដឹងទេ។ គ្រាន់ដឹងថា អ្នកដែលនៅជាប់គុកជាមួយគ្នាហ្នឹងចេះតែគេមិនដឹងរឿងអីៗផ្សេងៗគ្នា ខ្ញុំអត់បានដឹង។

**ស៖** បាទ អរគុណ។ តាមការកត់សម្គាល់របស់លោកស្រី ក្រៅពីស្ត្រីដែលជនជាតិចារ៉ាយដែលលោកស្រីថា បានចូលមក គេមកឃុំជាមួយបន្ទប់លោកស្រី តើមានស្ត្រីណាផ្សេងដែលឃុំជាមួយស្ត្រីហើយក្រោយមកត្រូវបាត់ខ្លួនគាត់ទេ?

**ឆ៖** ចាស ជនជាតិចារ៉ាយដែលមកនៅជាមួយពួកខ្ញុំហ្នឹង ក៏បាត់ៗមួយចំនួនដែរ ដែលថា ដូចខ្ញុំថាអ៊ីចឹង គេចងចេញទៅវិញទៅ ហើយនៅៗខ្លះ ទៅខ្លះ។

**ស៖** ចុះជនខ្មែរវិញ ដែលចងដែលៗនៅក្នុងឃុំនៅក្នុងបន្ទប់ជាមួយលោកស្រីហ្នឹង មានដែលបាត់ខ្លួនទេ?

[០៩:១១:០៤]

**ឆ៖** អត់បាត់ទៅណាទេ ជនជាតិខ្មែរហ្នឹង អត់ទៅណាផង។

**ស៖** តាមការសង្កេតរបស់លោកស្រី នៅពេលដែលលោកស្រីទៅរកបន្លែ ទៅធ្វើការនៅឆ្ងាយៗពីភូមិហ្នឹង តើលោកស្រីដែលបានជួបជាមួយប្រជាជនដែលរស់នៅជុំវិញមន្ទីរកែប្រែហ្នឹងដែរទេ ប្រជាជនដែលមិនមែនជាអ្នកទោស?

**ឆ៖** ចាស អត់មានទេ។ មានតែព្រៃ ៗស្ងាត់ឈឹង អត់ដែលជួបប្រជាជនណាផង។

**ស៖** បាទ អរគុណ។ កាលពីថ្ងៃព្រហស្បតិ៍មុនហ្នឹង លោកស្រីថា ឃើញរណ្ដៅសពមួយដែលហើមប្រេះមក ហើយដែលលោកស្រីឃើញរណ្ដៅហ្នឹង គឺក្រោយពីបាត់ជនជាតិចារ៉ាយ។ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់លោកស្រីថា ទីតាំងដែលលោកស្រីឃើញរណ្ដៅហ្នឹង នៅជុំវិញនោះមានឃើញមានដើមខ្នុរ ឬក៏ចម្ការខ្នុរច្រើនដែរទេ?

**ឆ៖** ព្រោះរណ្ដៅនុ៎ង ក៏ពួកខ្ញុំមិនបានឃើញចម្ការខ្នុរ ចម្ការអី ព្រោះអត់បានមើល បានអីទេលោកអើយ។ គ្រាន់ឃើញអ៊ីចឹង ចេះតែភ័យខ្លាច អត់មានក្រឡេកទៅមើលលិចកើតអីទេ។ ខំភ័យតែខ្លួនឯង អត់បានៗពិនិត្យរឿងចម្ការខ្នុរផង។

**ស៖** ទីកន្លែងដែលលោកស្រីថា ឃើញហ្នឹង ពីមុនមកលោកស្រីធ្លាប់ទៅដែរទេ?

**ឆ៖** ធ្លាប់ទៅ។

**ស៖** ហើយនៅទីនោះ លោកស្រីមានដែលសង្កេតថា មានចម្ការខ្នុរអីនៅជិតៗហ្នឹងដែរទេ?

[០៩:១៣:៣០]

**ឆ៖** អត់បានមើលរឿងចម្ការខ្នុរហ្នឹងផង។

**ស៖** ឥឡូវខ្ញុំចូលដល់សន្តិសុខឈ្មោះ អ៊ួយ ដែលលោកស្រីមានប្រសាសន៍អំមិញថា ធ្លាប់ឮគាត់និយាយ ថាគាត់ធ្លាប់ផឹកប្រមាត់។ តើលោកស្រីឮហ្នឹង គឺឮដោយផ្ទាល់ ឬក៏ឮដោយមានអ្នកណាមួយប្រាប់លោកស្រី?

**ឆ៖** គឺគាត់មកហូបបាយនៅផ្ទះបាយហ្នឹង គាត់ថា គាត់ធ្លាប់ផឹកប្រមាត់មនុស្ស គាត់ថា ខ្ញុំឮផ្ទាល់ណា។ ហើយចេញទៅគេនិយាយ ដូចថាស្រីៗគ្នាឯងទៀតក៏ថាដែរ គេថា តាអ៊ួយ ហ្នឹងធ្លាប់ផឹកប្រមាត់មនុស្ស។

**ស៖** គេដែលលោកស្រីឮហ្នឹង គាត់និយាយប្រាប់អ្នកណា ឬមួយក៏គាត់ប្រាប់ទាំងអស់គ្នាប្រកូកប្រកាសប្រាប់ទាំងអស់គ្នា?

**ឆ៖** គេនិយាយហ្នឹង ដូចថា គេមិនបានប្រកូកប្រកាសប្រាប់ពួកៗខ្ញុំហ្នឹងទេ។ គេនិយាយតែពួកគ្នាគេខាងសន្តិសុខដូចគ្នាហ្នឹង ដូចថា គេរបៀបគេថា គេនិយាយលេងគ្នាហ្នឹង គេថា "អ្ហ៎! អញធ្លាប់ផឹកប្រមាត់មនុស្សអ្ហ៎" អ៊ីចឹង។

**ស៖** តើលោកស្រីបានជួបឈ្មោះ អ៊ួយ ហ្នឹងរហូតដល់ពេលវៀតណាមចូល ឬក៏មុនវៀតណាមចូល លោកស្រីខានជួបគាត់នៅពេលណាមួយ?

**ឆ៖** ពេលដែលវៀតណាមចូលហ្នឹង គឺអត់ឃើញ តាអ៊ួយ ហ្នឹង តែឃើញអ្នកផ្សេងវិញ។

[០៩:១៦:០៩]

**ស៖** តើលោកស្រីខានឃើញ តាអ៊ួយ ហ្នឹងប៉ុន្មានខែមុនវៀតណាមចូល លោកស្រីអាចកត់សម្គាល់បានទេ?

**ឆ៖** ពេលដែលវៀតណាមចូលហ្នឹង គឺជ្រួលច្របល់ហ្នឹង ដូចថានាំគ្នាចេញទៅហ្នឹង បាត់ អត់ឃើញមុខ តាអ៊ួយ តែម្តង ពេលដែលជ្រួលច្របល់ ដែលវៀតណាមចូលហ្នឹង។

**លោក លីវ សុវណ្ណា៖**

បាទ សូមអរគុណលោកស្រី។ ខ្ញុំបាទអស់សំណួរ។ សូមអរគុណប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ជាបន្តទៅនេះ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះ សូមជម្រាបសួរភាគី ហើយសូមជម្រាបសួរលោកស្រីសាក្សី។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ជាដំបូង ខ្ញុំចង់ជម្រាបសួរអ្នកស្រីទាក់ទងការងាររបស់អ្នកស្រី ហើយខ្ញុំបានស្ដាប់ការរៀបរាប់របស់អ្នកស្រីកន្លងមកហើយ ទាក់ទងទៅនឹងការងារមួយចំនួន ប៉ុន្ដែខ្ញុំចង់បានព័ត៌មានជាក់លាក់ទាក់ទងទៅនឹងការងាររបស់អ្នកស្រី ជាពិសេសនៅមន្ទីរអប់រំអូរកន្សែង។ ខ្ញុំចង់សួរអ្នកស្រីថា នៅពេលដែលចូលទៅដល់ដំបូង នៅក្នុងមន្ទីរអូរកន្សែង អ្នកស្រីបានរៀបរាប់ថា ដើរបេះបន្លែសម្រាប់ផ្គត់ផ្គង់នៅក្នុងមន្ទីរអូរកន្សែងហ្នឹង តើអ្នកស្រីធ្វើកិច្ចការហ្នឹងក្នុងរយៈពេលប៉ុនណាដែរ ចាប់ពីពេលណា ដល់ពេលណា?

[០៩:១៨:០៩]

**លោកស្រី មឿង ចាន់ឌី៖**

**ឆ៖** ពេលដែលនាងខ្ញុំទៅដល់ហ្នឹង គេក៏មិនបានឲ្យយើងដើរបេះបន្លែបេះអីដែរទេ។ គេនៅឃុំយើង ឬក៏នៅផ្ទះខុមហ្នឹង។ ទាល់តែយូរ ដែលគេទុកចិត្ត ដូចថាយើងអត់រត់អត់អីហ្នឹង បានគេឲ្យយើង។ ពេលដែលឆ្លងទន្លេហើយ បានគេឲ្យខ្ញុំដើរបេះបន្លែ ទៅធ្វើការធ្វើអីហ្នឹង បានដើរទៅ។ ពេលដែលខ្ញុំទៅហ្នឹង គឺគេឲ្យនៅសិន។ គេមើលថា យើងហ្នឹងអត់រត់អត់អី អាហ្នឹងបានគេឲ្យយើងហ្នឹងចេញធ្វើការចេញបេះបន្លែអីតិចតួច។ ហ្នឹងគេទុកចិត្ត។

**ស៖** បាទសូមអរគុណ។ តាមខ្ញុំចាំសក្ខីកម្មរបស់អ្នកស្រីដែលបានផ្ដល់ពីសប្ដាហ៍មុន ថាអ្នកស្រីត្រូវបានឃុំខ្លួននៅកន្លែងឃុំខ្លួននៅមន្ទីរអូរកន្សែងហ្នឹង តែមួយយប់ទេ នៅពេលដែលទៅដល់ដំបូង។ ហើយក្រោយមក អ្នកស្រីត្រូវបានបញ្ជូនទៅនៅកន្លែងផ្សេង ក្នុងផ្ទះផ្សេង ដែលមិនមានការចាក់សោរពីក្រៅនោះទេ។ អ៊ីចឹងខ្ញុំចង់បញ្ជាក់ថា តើលោកស្រីនៅក្នុងកន្លែងដែលក្រៅពីកន្លែងឃុំឃាំងមួយយប់ហ្នឹង អ្នកស្រីរស់នៅចាប់ពីពេលណា ដល់ពេលណាដែរ?

**ឆ៖** ចេញពីកន្លែងឃុំឃាំង គឺនៅយូរដែរ រយៈពេលពីរបីខែអីទៅ។

**ស៖** អ្នកស្រីអាចបញ្ជាក់ទីតាំងជាក់លាក់កន្លែងផ្ទះមួយ ដែលលោកស្រីរស់បន្ទាប់ពីចេញពីកន្លែងឃុំឃាំងហ្នឹងទេ កន្លែងដែលលោកស្រីថា ត្រូវបានគេឃុំខ្លួនមួយយប់នោះ ពេលដែលចេញពីហ្នឹងទៅ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លោកស្រីទៅនៅកន្លែងណា? ហើយកន្លែងហ្នឹងមានទីតាំងជាក់លាក់ត្រង់ណាដែរ លោកស្រីអាចបញ្ជាក់បានទេ វានៅកន្លែងខាងជើង ឬខាងត្បូង ខាលិច ខាងកើតនៃកន្លែងឃុំឃាំង ឬក៏កន្លែងសួរចម្លើយអី? អ្នកស្រីអាចបញ្ជាក់ពីទីតាំងច្បាស់លាស់បានទេ?

[០៩:២០:៤៤]

**ឆ៖** ពេលដែលគេឃុំខ្លួនហ្នឹង គឺយើងចូលទៅ គឺយើងនៅកន្លែងឃុំខ្លួនហ្នឹងប្រហែលជាខ្ទមមួយមានបិទទ្វារបិទអី។ ដល់ពេលចេញពីអាហ្នឹង ចេញពីកន្លែងបិទទ្វារ បិទអីហ្នឹងមក មកនៅអាខ្ទមមួយដែលថា អគាររាងវែងបន្តិចហ្នឹង ប្រក់បន្ទាំ ហើយខាងក្រោយក៏បន្ទាំឫស្សីហ្នឹងដែរ ប៉ុន្តែខាងមុខចំហទាំងអស់ គេឱ្យនៅហ្នឹង នៅហ្នឹងទាំងអស់គ្នាទៅ។

**ស៖** ទាំងអស់គ្នាហ្នឹង អ្នកស្រីមានអ្នកណាខ្លះ? អាចបញ្ជាក់បានទេ ទាំងអ្នកទោសអ្នកទាំងអស់ ឬមួយក៏ក្នុងក្រុមណាមួយដែលអ្នកស្រីអាចស្គាល់បាន?

**ឆ៖** គ្នាដែលទៅជាមួយខ្ញុំ ជិះឡានទៅជាមួយខ្ញុំប៉ុន្មានគ្រួសារហ្នឹង ពីរបីគ្រួសារហ្នឹង ទាំងខ្ញុំទាំងអីហ្នឹង គឺនៅហ្នឹងទាំងអស់គ្នាហ្នឹង។

**ស៖** បើតាមខ្ញុំចាំ គឺអ្នកដែលចេញពីចម្ការកៅស៊ូជាមួយអ្នកស្រីទៅមានបីគ្រួសារ រាប់ទាំងគ្រួសារអ្នកស្រីផង ហើយអ្នកស្រីបានបញ្ជាក់ថា មានប្ដីមានប្រពន្ធគ្រប់គ្នាអីចឹង។ អីចឹងមានន័យថា បីនាក់ដែលចេញពីចម្ការកៅស៊ូជាមួយអ្នកស្រីហ្នឹងស្ថិតនៅក្នុងអគារ ឬក៏ផ្ទះវែងជាមួយគ្នា ជាមួយនឹងលោកស្រី។ ចុះមានអ្នកផ្សេងទៀតក្រៅពីអ្នកបីនាក់ហ្នឹង -- អ្នកពីរនាក់ហ្នឹងទៀតទេ ដែលរស់នៅក្នុងអគារវែងហ្នឹង?

**ឆ៖** អ្នកផ្សេងមានជនជាតិចារ៉ាយជនអី ហើយដឹងមកពីណាពីណី ខ្ញុំអត់ដឹងដែរ។ ប៉ុន្តែខ្ញុំដូចថាជិតស្និទ្ធជាងគេមានតែពីរបីគ្រួសារដែលមកជាមួយគ្នាហ្នឹង។

[០៩:២២:៥៨]

**ស៖** អ្នកស្រីមានចាំអ្នកណាផ្សេងទៀតទេ ក្រៅពីពីរគ្រួសារផ្សេងទៀតដែលចេញពីចម្ការកៅស៊ូទៅជាមួយគ្នា?

**ឆ៖** នាងខ្ញុំអត់ចាំផង ព្រោះអីដឹងគេមកពីណាពីណីនៅហ្នឹងដែរ ប៉ុន្តែអត់ស្គាល់គេ ហើយអត់ចាំ។

**ស៖** អ្នកស្រីចាំបានថាមានចំនួនមនុស្សប៉ុន្មាននាក់ដែរ បើក្នុងជាមធ្យមក្នុងពេលរស់នៅក្នុងអគារ

វែងហ្នឹង?

**ឆ៖** នៅអរគារវែងនុ៎ង ចំនួនមនុស្សដែលនាងខ្ញុំអត់ស្គាល់ ហើយដឹងគេមកពីណាពីណី ប្រហែលជាបីទៅបួននាក់ ស្រីៗ។

**ស៖** បាទ សូមអរគុណ។ នៅពេលដែលអ្នកស្រីស្ថិតនៅក្នុងអគារវែងហ្នឹង អ្នកស្រីធ្វើអីខ្លះ គេឲ្យអ្នកស្រីធ្វើអីខ្លះ? ហើយអ្នកផ្សេងទៀត ដែលនៅក្នុងអគារវែងជាមួយអ្នកស្រីហ្នឹង គេធ្វើអីខ្លះដែរ?

**ឆ៖** គេចែកមុខងារគ្នាទៅ ដូចអ្នកខ្លះគេទៅជម្រះស្មៅអីចឹងទៅ អ្នកខ្លះគេទៅកាប់ព្រៃ ហើយអ្នកខ្លះគេឲ្យទៅបេះបន្លែ។

**ស៖** បាទ សូមអរគុណ។ ចុះចំពោះអ្នកស្រីផ្ទាល់ អ្នកស្រីធ្វើការងារអីដែរ?

**ឆ៖** នាងខ្ញុំ គេឲ្យបេះបន្លែ គេឲ្យនៅផ្ទះបាយ។

[០៩:២៥:១៩]

**ស៖** បាទសូអរគុណ។ ចុះពេលវេលាដែលអ្នកស្រីនៅក្នុងផ្ទះវែងហ្នឹង គឺនៅសម្រាកនៅពេលយប់ ហើយនៅពេលថ្ងៃលោកស្រីចេញទៅធ្វើការ ដែលលោកស្រីថាទៅបេះបន្លែ ឬក៏ទៅធ្វើការនៅផ្ទះបាយ។ តើអីចឹងត្រឹមត្រូវទេ?

**ឆ៖** ត្រឹមត្រូវ។

**ស៖** អ្នកស្រីចំណាយពេលនៅពេលថ្ងៃនៅក្នុងអគារវែងហ្នឹងដែរទេ ឬក៏អ្នកស្រីមិនដែលនៅពេលថ្ងៃទេ គឺមានពេលយប់ទេ បានអ្នកស្រីមកសម្រាកនៅក្នុងអគារវែងហ្នឹង?

**ឆ៖** ដេកនៅពេលយប់ ថ្ងៃចេញធ្វើការ។

**ស៖** អគារវែង ដែលលោកស្រីស្នាក់ហ្នឹង លោកស្រីធ្លាប់មានប្រសាសន៍ក្នុងសក្ខីកម្មពីមុនថាមានចម្ងាយ៣០ម៉ែត្រពីកន្លែងសួរចម្លើយ ហើយក្រោយមកក៏មានឆ្លើយថាប្រហែល២០ម៉ែត្រ។ ដូច្នេះវាអាចចន្លោះពី២០ម៉ែត្រទៅ៣០ម៉ែត្រពីកន្លែងសួរចម្លើយ។ តើអ្នកស្រីនៅចាំសក្ខីកម្មហ្នឹងទេ?

**ឆ៖** ព្រោះនាងខ្ញុំបានជម្រាបថា នាងខ្ញុំនៅកន្លែងនោះក៏មិន ដូចថាមិនចេះដឹងថាស្មាន ជួនកាលស្មានគឺគ្មាន លើស ហើយនិងខ្វះ។ ដូច្នេះនិយាយទៅគឺមិនត្រឹមត្រូវ ព្រោះខ្ញុំវាអត់ ដូចថាអត់សួរប្រសប់គេហៅថាស្មាន ហើយនិងប្រវែងអី គិតគីឡូគីអី គឺអត់ចេះទេ ព្រោះការរស់នៅកន្លែងនោះ ដឹងថាព្រលឹមឡើងដូចថា ដល់ម៉ោងបាប់ម៉ោងរស់។ ដូច្នេះមិនបានគិតពិរណាអីវែងឆ្ងាយសព្វគ្រប់បែបយ៉ាងអីទេ គិតថាបើដេកទៅភ្លឺឡើងរស់ គឺរស់បានម៉ោងទៅ។ ដូច្នេះនាងខ្ញុំមិនបានគិតវែងឆ្ងាយគីឡូអីទេ ព្រោះការស្មាន គឺមាន

លើស និងខ្វះ ព្រោះយើងចេះតែស្មានយក ស្មានយក មិនដឹងថាប្រហែល២០ម៉ែត្រ ឬក៏៣០ម៉ែត្រ គឺមិនដឹងដែរ។

[០៩:២៨:០០]

**ស៖** បាទ សូមអរគុណ ខ្ញុំយល់។ ខ្ញុំចង់សួរបន្តទៀត តើអ្នកស្រីបានចាកចេញពីអគារវែងទៅរស់នៅកន្លែងផ្សេងទៀតទេ ឬមួយក៏អ្នកស្រីរស់នៅក្នុងអគារវែងនោះរហូត ចាប់តាំងពីពេលចូលទៅមន្ទីរអូរកន្សែងនោះ រហូតដល់ពេលវៀតណាមចូល?

**ឆ៖** នាងខ្ញុំរស់នៅអគារហ្នឹងរហូតទៅដល់វៀតណាមចូល បានគេបញ្ចេញទៅតែម្តង អត់មានដូរអគារទេ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សួរអ្នកស្រីឱ្យបានច្បាស់ថែមទៀតទាក់ទងទៅនឹងការងាររបស់អ្នកស្រី ដែលលោកស្រីបានបញ្ជាក់មុននេះថា អ្នកស្រីធ្វើការភាគច្រើននៅក្នុងចង្ក្រានបាយនិងបេះបន្លែ។ ហើយពេលវេលាមួយ ដែលអ្នកស្រីអាចចាំបាន គឺពេលវេលាក្រោយពីការសម្រាកកូនរបស់អ្នកស្រី។ ខ្ញុំចង់សួរថា តើក្រោយពីៗសម្រាលកូនរបស់អ្នកស្រី អ្នកស្រីទៅធ្វើការអីផ្សេងទៀតទេ ឬក៏ការងារហ្នឹងនៅតែធ្វើការទាក់ទងនឹងចង្ក្រានបាយ ហើយនិងការងាររកបន្លែហ្នឹងដែរ?

**ឆ៖** ពេលដែលនាងខ្ញុំសម្រាលកូនរួចហ្នឹង គេក៏ឱ្យនៅចង្ក្រានបាយហើយ ក៏គេឱ្យទៅលីឈើ។ លីឈើចេញពីព្រៃចូលវាល វាលចូលព្រៃ អត់មានផ្លូវទេ គឺរុកទៅតាមដើមឈើហ្នឹង។ អាហ្នឹងគេប្រើខ្ញុំទៅលីក្តារដែរ ធ្វើការធ្ងន់ៗ។

[០៩:៣០:២០]

**ស៖** បាទ សូមអរគុណ។ លោកស្រីបានបញ្ជាក់ហើយកាលពីសប្តាហ៍មុនទាក់ទងទៅនឹងការលីក្តារ អ្នកស្រីបានបង្ហាញថា វាមានចម្ងាយប្រហែលពីផ្លូវបត់ចូលតុលាការហ្នឹង ពីផ្លូវខាងមុខនោះ ផ្លូវជាតិហ្នឹងចុះមកកន្លែងសាលជំនុំជម្រះនេះ។ ខ្ញុំចង់សួរបញ្ជាក់បន្ថែមថា រយៈពេលប៉ុន្មានដែរដែលអ្នកស្រីធ្វើការលីក្តារហ្នឹង?

**ឆ៖** គេឱ្យលីក្តារហ្នឹង ដូចថាយើងគេចង់ធ្វើមន្ទីរអីមួយ ដូចថាមន្ទីរគេធ្វើដោយអំពីឈើ ឬក៏អីហ្នឹង គេឱ្យយើងទៅលីឈើ រួចពីក្តារទៅ ឈើអីផ្សេងៗអ៊ីចឹងមក ទាល់តែបានបួនដប់ថ្ងៃអីទៅ គេៗឱ្យយើងធ្វើការអីផ្សេង។ ដូចថាគេចែកការងារអ៊ីចឹង ដូចថាឥឡូវថ្ងៃនេះគេមានការងារឱ្យយើងធ្វើលីក្តារ។ ថ្ងៃស្អែកអ៊ីចឹងទៅ គេហៅទៅលីអាឈើមូលៗអីអ៊ីចឹងទៅ ឬក៏ថាស្អែកមួយទៀតទៅ គេឱ្យទៅយើងទៅ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លីបន្ទាំអីអ៊ីចឹងទៅ។ គេចែកការងារធ្វើជាប្រចាំថ្ងៃរបស់គេអ៊ីចឹងទៅ ហើយយើងចេះតែធ្វើទៅ។ មានធ្ងន់ខ្លះ មានស្រាលខ្លះអ៊ីចឹងទៅ មានលំបាកខ្លះ មានអីអ៊ីចឹង។ ប្រហែងលីក្តារហ្នឹង បើយើងនិយាយពីផ្លូវចូលមក យើងមានផ្លូវអ៊ីចឹង គឺថាដូចជាជិត ប៉ុន្តែបើសិនជាយើងលី អត់មានផ្លូវទេ គឺយើងលីកាត់ព្រៃតែម្តង ព្រៃល្បាស់ៗ មានដើមឈើហ្នឹងចេះតែលីមក គឺឃ្យូរណាស់ ហើយឆ្ងាយ សឹងតែមិន ចង់មួយថ្ងៃអីនោះ។ ព្រោះអីវាអត់ផ្លូវ ហើយចេះតែលីទៅ ធ្ងន់នោះ វាគេចពីដើមឈើនេះ ទៅទើសអានេះ លើកទៅទើសអាក្រោយ លើកទើសអាមុខ អ៊ីចឹង។

**ស៖** បាទ សូមអរគុណ។ តាមខ្ញុំចាំអំមិញ អ្នកស្រីឆ្លើយថាប្រហែលជា១០ថ្ងៃ ក្នុងការងារលីក្តារ លីឈើហ្នឹង។ ខ្ញុំចង់សួរបន្តថា តើគម្រោងសាងសង់អគារហ្នឹង បានធ្វើហើយឬនៅ ឬមួយក៏ក្តារហ្នឹង គ្រាន់តែយកមកហើយមិនទាន់បានសាងសង់ទេ រហូតដល់ពេលបែកវៀតណាម?

[០៩:៣៣:០៤]

**ឆ៖** អគារហ្នឹង ដឹងជាគេមិនទាន់សាងសង់អីប៉ុន្មានទេ ដូចថាគេយកទៅវ៉ៃ អារបៀបអគារគេអ្នកធំអីនៅហ្នឹង គេវ៉ៃពីខាងពីអី ដូចថាគេជួសជុលអីលិចកើតអីហ្នឹង ខ្ញុំក៏មិនសូវដឹងដែរ មិនសូវចាប់អារម្មណ៍អីទេ។ បើថាគេឲ្យលីក្តារ យកទៅទម្លាក់ទៅព្រួសទៅ ហើយហីទៅ មិនមានអារម្មណ៍ឯណាទៅគិតថាអ្នេអ្នកឯងធ្វើអី ធ្វើអី អត់បានគិតទេ ព្រោះដូចខ្ញុំលើកឡើងអ៊ីចឹងថា ការរស់នៅកន្លែងនោះមានតែម៉ែ្ងងាប់ម៉ែ្ងរស់ហ្នឹង។ ហើយអ៊ីចឹងយើងទៅដឹងឮអីសព្វបែបយ៉ាង គឺអត់បានដឹងបានឮទេ។ អ្វីដែលខ្ញុំឃើញនឹងភ្នែក អ្វីដែលខ្ញុំដឹងគឺខ្ញុំនិយាយទៅ។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីមានធ្វើការងារអីទៀតទេ ក្រៅពីអាការងារចុងភៅ រកបន្លែ ហើយនិងអាលីក្តារអម្បាញ់មិញ ដែលលោកស្រីមានប្រសាសន៍អំមិញហ្នឹង មានការងារអីផ្សេងទៀតទេ?

**ឆ៖** អត់មានការងារផ្សេងទេ មានតែដដែលហ្នឹង។

**ស៖** បាទ សូមអរគុណ។ ខ្ញុំមានសំណួរមួយផ្សេងទៀតទាក់ទងទៅនឹងសក្ខីកម្មរបស់លោកស្រីដែលលោកស្រីបានបញ្ជាក់ថា មានស្ត្រីម្នាក់បានប្រាប់អ្នកស្រីទាក់ទងទៅនឹងការធ្វើទារុណកម្មប្តីរបស់គាត់។ លោកស្រីអាចបញ្ជាក់ពេលវេលាបានទេក្នុងពេលហ្នឹង គឺស្ថិតនៅក្នុងពេលវេលាណា? បានន័យថាអាចចាំឆ្នាំ ឬក៏ខែបានទេ?

[០៩:៣៥:១៥]

**ឆ៖** នាងខ្ញុំអត់ចាំទេ។ អត់ចាំឆ្នាំ អត់ចាំខែ។

**ស៖** បាទ សូមអរគុណ។ ចុះពេលដែលស្ត្រីម្នាក់ហ្នឹងនិយាយរឿងថា ប្តីរបស់គាត់មើលទៅដូចជាជរា ប្រហែលជាគេត្រូវធ្វើទារុណកម្ម។ គេនិយាយជាមួយអ្នកស្រីនៅពេលណាដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណលោកប្រធាន។ ប្រសិនបើខ្ញុំចាំមិនខុសទេ សក្ខីកម្មរបស់សាក្សីបានថា មានស្ត្រីជាច្រើនបានប្រាប់គាត់ថា ប្តី<របស់ពួកគេ>ត្រូវបានគេធ្វើទារុណកម្ម។ ដូច្នេះខ្ញុំគិតថា មេធាវី<>កំពុងតែ<បង្រួម>សក្ខីកម្មរបស់សាក្សី<ហួសហេតុពេកហើយ ដោយ>និយាយថា មានស្ត្រីតែម្នាក់ គឺខ្ញុំចង់មានន័យថា គាត់កំពុងតែផ្លាស់ប្តូរភ័ស្តុតាង។ ដូច្នេះខ្ញុំចង់ឲ្យគាត់បញ្ជាក់ឲ្យបានច្បាស់ ថាតើហេតុការណ៍ណាមួយដែលគាត់កំពុងតែនិយាយ។ សូមអរគុណ។

**លោក គង់ សំអុន៖**

បាទ ក្នុងសក្ខីកម្មនេះ ខ្ញុំនឹងសួរសាក្សីដើម្បីឲ្យគាត់បញ្ជាក់។

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោកស្រី តើលោកស្រី តើលោកស្រីចាំបានទេថា មានស្ត្រីប៉ុន្មាននាក់ដែលនិយាយប្រាប់លោកស្រីថា ប្តីត្រូវធ្វើទារុណកម្ម?

[០៩:៣៦:៥២]

**លោកស្រី មឿង ចាន់ឌី៖**

**ឆ៖** គឺស្ត្រីដែលនៅជាមួយខ្ញុំហ្នឹង វាពីរបីគ្រួសារហ្នឹង គឺពេលដែលគេហៅទៅសួរម្តងម្នាក់ ម្តងម្នាក់ ដូច្នេះស្ត្រីគេសួរមុន បុរសគេសួរក្រោយ។ ហើយដូច្នេះវាប្តីប្រពន្ធហ្នឹង ដែលឃើញប្តីចូលទៅកន្លែងសួរចម្លើយហ្នឹង គឺប្រពន្ធហ្នឹងចេះតែដូចថា ចាំមានអារម្មណ៍ថា ភិតភ័យអីអ៊ីចឹងទៅ។ ដល់ពេលប្តីចេញមកវិញហ្នឹង ក៏ឃើញសភាពអត់ល្អអ៊ីចឹង ក៏រៀបរាប់និយាយថា "អ្ហ៎ ប្តីខ្ញុំប្រហែលជាគេវាយ គេឆក់ខ្សែភ្លើងអីអ៊ីចឹងហើយ។" មកនិយាយពិគ្រោះគ្នាដែលនៅជាមួយស្រីៗដូចគ្នាហ្នឹង ថា បើអ៊ីចឹងមើលគាត់ដើរអត់ត្រង់ អីអ៊ីចឹង។ ធម្មតាមនុស្សដែលយើងដើរទៅអត់ឈឺ អត់អី ធម្មតាមនុស្សដើររឹងប៉ឹង ចុះបើត្រឡប់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មកវិញ រាងទ្រុឌទ្រោមហើយ មិនៗថា គេវាយ។ យើងមិនៗថា គេវាយម៉េច។ ម្ល៉ោះហើយប្រពន្ធហ្នឹងចេះតែចាប់អារម្មណ៍ថា គេវាយប្ដីហើយ ឬក៏ឆក់ខ្សែភ្លើងអីហើយ បានប្ដីខ្ញុំទ្រុឌទ្រោមអ៊ីចឹង។ ហ្នឹងហើយស្ត្រីគេថាអ៊ីចឹង។ គេនិយាយប្រាប់ខ្ញុំអ៊ីចឹង។

**ស៖** បាទ សំណួររបស់ខ្ញុំ ខ្ញុំចង់ដឹងពីចំនួនជាក់លាក់ ថាតើស្ត្រីប៉ុន្មាននាក់ដែលបាននិយាយជាមួយអ្នកស្រីអំពីថា ប្ដីរបស់ពួកគេត្រូវធ្វើទារុណកម្មនោះ?

**ឆ៖** ព្រោះស្ត្រីម្នាក់ហ្នឹងបាននិយាយជាមួយខ្ញុំ ហើយក្រៅពីហ្នឹងទៀត គេអត់ឮនិយាយអីផង។ ប៉ុន្តែគេគ្រាន់ថា នៅជំនុំចំណោមជុំគ្នាហ្នឹង គេពិគ្រោះគ្នាថា ប្រាកដជា បុរសប្រាកដជាបានគេធ្វើទារុណកម្មហើយ ទាំងៗស្រីៗទាំងអស់ហ្នឹង គេៗថាអ៊ីចឹងទៅ។ ហើយយើងក៏មិនបានទៅតាមដានមើលគេអ៊ីចឹង វាទូទៅហើយ។ ដូចថាប្ដីគេក៏ដូចប្ដីខ្ញុំ ប្រហែលជាដូចតែគ្នាហ្នឹង ព្រោះបុរសៗគេធ្វើបាបអ៊ីចឹង គេទាំងអស់តែគ្នាហ្នឹង។

[០៩:៣៩:០៦]

**ស៖** បាទ សូមអរគុណ។ អ្នកស្រីចាំថា អ្នកស្រីនិយាយជជែកគ្នាហ្នឹងនៅកន្លែងណាដែរទេ?

**ឆ៖** នៅក្នុងអគារដេកហ្នឹង។

**ស៖** ពេលណាដែរ ថ្មើរណាដែរ អ្នកស្រីអាចចាំបានទេ?

**ឆ៖** ពេលប្រហែលជាម៉ោងបី ម៉ោងបីបួនអីហ្នឹង ព្រោះអីគេសួរចម្លើយពេលព្រឹកអ៊ីចឹងទៅ ខ្លះរហូតទៅដល់ម៉ោងបីបួនអីអ៊ីចឹង។ ហើយដល់ៗដំណាក់កាលនោះ ប្ដីមីងនុ៎ង គាត់ដូចថាទុរន់ជាងគេហ្នឹង ក៏គាត់និយាយប្រាប់នាងខ្ញុំទៅ។

**ស៖** បាទ តើវាមានន័យថា ពេលដែលអ្នកស្រីនិយាយគ្នាហ្នឹង មិនមែននៅពេលដែលសួរចម្លើយទេ គឺក្រោយពេលសួរចម្លើយរួចហើយ ហើយអាចថាអ្នកស្រីត្រឡប់មកពីធ្វើការងារវិញ។ តើអ៊ីចឹងទេ?

**ឆ៖** ពេលដែលនុ៎ង មិនទាន់ទៅធ្វើការទេ ព្រោះសួរ ថ្ងៃសួរចម្លើយហ្នឹងគឺនៅទាំងអស់ ទាំងស្ត្រីទាំងបុរស។ គេអត់ទាន់ឲ្យចេញទៅណាទៅណីទេ គេឲ្យយើងសួរចម្លើយស្ត្រីរួច សួរចម្លើយបុរស ហ្នឹងគេនៅ និយាយទៅ គេមិនទាន់ទុកចិត្តយើង ឲ្យយើងទៅធ្វើការធ្វើអីងារអីទេ។ គេឲ្យនៅមួយកន្លែងសិនហ្នឹងហើយ នៅក្នុងអគារហ្នឹងសិន។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរអ្នកស្រីទាក់ទងទៅនឹងជនជាតិចារ៉ាយ ដែលលោកស្រីរៀបរាប់ថា ឃើញជនជាតិចារ៉ាយមួយចំនួន មានស្ត្រី មានក្មេងចូលមកក្នុងអគាររបស់អ្នកស្រី។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អ្នកស្រីចង់និយាយពីអគារដែលអ្នកស្រីស្នាក់នៅជាមួយអ្នកដទៃទៀត បីបួននាក់ផ្សេងទៀតហ្នឹង មែនទេ?

[០៩:៤១:៣៧]

**ឆ៖** អគារនៅជាមួយខ្ញុំ សូមម្ដងទៀតដូចអត់ច្បាស់។

**ស៖** ខ្ញុំចង់ឲ្យអ្នកស្រីបញ្ជាក់ថា ជនជាតិចារ៉ាយដែលលោកស្រីថា ប្រហែលជា២០នាក់ត្រូវបាននាំចូលមកនៅក្នុងអគាររបស់អ្នកស្រី ហើយខ្ញុំចង់សួរបញ្ជាក់ថា ជាអគារដែលលោកស្រីស្នាក់នៅពេលយប់ៗហ្នឹង មែនទេ?

**ឆ៖** ចាស អគារនៅជាមួយគ្នា។

**ស៖** លោកស្រីបានបញ្ជាក់ហើយថា ពេលដែលជនជាតិចារ៉ាយចូលមក គឺមានជាប់ចំណងជាប់ចំណងមួយខ្សែវែង។ អ៊ីចឹងពេលដែលមកដល់ហ្នឹង តើគេមានស្រាយចំណងទេ ពេលដែលមកដល់ក្នុងអគារ?

**ឆ៖** មកដល់ក្នុងអគារ អត់ទាន់ស្រាយទេ។

**ស៖** រហូតដល់ពេលណា បានស្រាយដែរ ឬក៏មិនស្រាយទេ?

**ឆ៖** គេអត់ទាន់ស្រាយ គេធ្វើដូចថាទុកសិន ទាល់តែគេទុកចិត្តអ៊ីចឹង ដូចពួកខ្ញុំមកដំបូងដែរហ្នឹង ហើយអ៊ីចឹងបានគេស្រាយ។ ដល់ពេល រយៈពេលគេទុកចិត្តថ្លើមថា អ្ហ៎! អត់រត់ទេ ឬក៏ស្រីៗហ្នឹងរត់ទៅណាអត់រួចទេ អ៊ីចឹងគេ បានគេស្រាយ។

[០៩:៤៣:២២]

**ស៖** បាទ សំណួររបស់ខ្ញុំ អ្នកស្រីចាំរយៈពេលហ្នឹងទេ រយៈពេលពីពេលដែលគេចង រហូតដល់គេស្រាយហ្នឹង ដែលៗអ្នកស្រីថា រហូតដល់គេទុកចិត្តហ្នឹង រយៈពេលប៉ុន្មានដែរ? ប៉ុន្មានថ្ងៃ?

**ឆ៖** ដូចមិនដឹងប៉ុន្មានថ្ងៃផង ព្រោះយើងទៅធ្វើការបាត់ៗទៅ មិនដឹងរាប់ថ្ងៃ ដឹងប៉ុន្មានថ្ងៃផង។ បើជួនទៅ មកទៅ ជួនឃើញគេស្រាយទៅ ប៉ុន្តែមិនដឹងប៉ុន្មានថ្ងៃ គឺខ្ញុំអត់បានដឹង។

**ស៖** បាទ សូមអរគុណ។ លោកស្រីចាំថា មានជនជាតិចារ៉ាយចូលមកក្នុងទ្រង់ទ្រាយធំបែបហ្នឹង ប៉ុន្មានដងដែរ ក្នុងរយៈពេលដែលលោកស្រីនៅមន្ទីរអប់រំអូរកន្សែងហ្នឹង?

**ឆ៖** នាងខ្ញុំបាន ទើបបានឃើញតែម្ដងហ្នឹង។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សួរបញ្ជាក់អ្នកស្រីថា តើមានហេតុផលអីដែលអ្នកស្រីអាចចាំ

បានថា អ្នកដែលចូលមក ដែលជាប់ចំណាងមានគ្នា២០នាក់ ប្រហែល២០នាក់ហ្នឹងជាជនជាតិចារ៉ាយ? អ្នកស្រីបានបញ្ជាក់ពីការប្រើភាសា ពីសប្តាហ៍មុន ប៉ុន្តែខ្ញុំចង់សួរថា មានអ្វីបន្ថែមក្រៅពីហ្នឹងទេ ដែលអាចឲ្យអ្នកស្រីដឹងថា អ្នកទាំងនោះជាជនជាតិចារ៉ាយ?

**ឆ៖** នាងខ្ញុំកត់សម្គាល់ថា ដូចនាងខ្ញុំនៅរតនគិរី នាងខ្ញុំដឹងពាក្យទំពួន ពាក្យជនជាតិចារ៉ាយ ឃើញគេនិយាយផ្សេងៗគ្នា។ ដូច្នេះពេលដែលជនជាតិចារ៉ាយចូលមក គឺនាងខ្ញុំសង្កត់ៗថា ជនជាតិចារ៉ាយ ព្រោះខ្ញុំដឹងភាសាគេនិយាយ។

**ស៖** បាទ សូមអរគុណ។ លោកស្រីខ្លួនឯងផ្ទាល់មានចេះភាសាជនជាតិចារ៉ាយហ្នឹងខ្លះដែរទេ?

**ឆ៖** ជនជាតិចារ៉ាយអត់សូវចេះ អត់ចេះតែម្តង។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីមានទំនាក់ទំនង ឬនិយាយអ្វីជាមួយអ្នកទាំងអស់នោះ ដើម្បីបញ្ជាក់ថា ពួកគេជាជនជាតិចារ៉ាយដែរទេ?

[០៩:៤៦:១៤]

**ឆ៖** អត់មានទំនាក់ទំនងគ្នាអីទេ ប៉ុន្តែដឹងថា ជនជាតិចារ៉ាយតែម្តង។ នាងខ្ញុំថា ជនជាតិចារ៉ាយ ព្រោះនាងខ្ញុំដឹងថា គេនិយាយជនជាតិចារ៉ាយហ្នឹង ភាសាអ៊ីចេះ ហើយភាសាទំពួនហ្នឹងគេនិយាយអ៊ីចេះ ហើយភាសាកាចក់ហ្នឹង គេនិយាយអ៊ីចេះ។ អាហ្នឹងខ្ញុំដឹង។

**ស៖** បាទសូមអរគុណ។ អ្នកស្រីអាចបញ្ជាក់ពីរយៈពេលណាមួយដែលអ្នកស្រីអាចសម្គាល់បានថា តើជនជាតិចារ៉ាយហ្នឹង មកចូលក្នុងអគារ មកស្នាក់នៅក្នុងអគារវែងជាមួយអ្នកស្រីហ្នឹងបានរយៈពេលប៉ុន្មានដែរ?

**ឆ៖** ដូចរស់នៅជាមួយនាងខ្ញុំហ្នឹង ដូចរយៈពេលមិនយូរប៉ុន្មានដែរទេ។

**ស៖** បាទ សូមអរគុណ។ នៅពេលដែលលោកស្រីស្នាក់នៅជាមួយគ្នា ជាពិសេសគឺតាមសម្តីរបស់អ្នកស្រីថា នៅពេលយប់អ្នកស្រីស្នាក់នៅក្នុងអគារហ្នឹងជាមួយគ្នា។ អ៊ីចឹងអ្នកស្រីមានសម្គាល់អ្វីទៅលើជនជាតិចារ៉ាយទាំងអស់នោះដែរទេ ជាលក្ខណៈពិសេសណាមួយដែលអ្នកស្រីអាចសម្គាល់ទៅលើសម្លៀកបំពាក់របស់គាត់ហ្នឹង?

**ឆ៖** ពេលដែលជនជាតិចារ៉ាយហ្នឹង នៅដេកមួយចំហៀងពួកខ្ញុំហ្នឹង សម្គាល់ដូចថា ឥឡូវដូចខ្ញុំថា លោកតុលាការអ៊ីចឹង ខាងមុខពាក់ក្រហម ហើយខាងចំហៀងខ្ញុំពាក់ស្វាយ ខាងនេះពាក់ខ្មៅអ៊ីចឹង ហើយម៉ូដផ្សេងៗគ្នា ដូចគ្នាអ៊ីចឹង គឺខ្ញុំកត់សម្គាល់ថា ដឹងថាយាយប៊ុនុំងគាត់ពាក់ពណ៌ក្រហម ហើយ

មានសពីមុខអីអ៊ីចឹងទៅ។ អ៊ីចឹងដឹងថា ជនជាតិចាវ៉ាយហ្នឹងពាក់ខោអាវហ្នឹង ពណ៌ក្រហម ហើយឬមាន ម៉ូដអីដូចយ៉ាងម៉េច ដែលយើងកត់សម្គាល់បានហ្នឹង គឺខ្ញុំដឹងថា គេពាក់អ៊ីចឹង។

[០៩:៤៩:០៩]

**ស៖** បាទ សូមអរគុណ។ គេស្លៀកពាក់ដូចៗគ្នា ឬក៏ខុសគ្នា?

**ឆ៖** គេស្លៀកពាក់អត់ដូចគ្នាទេ ដូចថា គេស្លៀកពាក់របៀបនៅក្នុងគ្រួសារអ៊ីចឹង លក្ខណៈនៅ ប្រជាជនសាមញ្ញអីនៅក្នុងភូមិ ក្នុងស្រុកអ៊ីចឹង។ អត់មានខោអាវអីដូចៗគ្នាទេ។ ខ្លះអ៊ីចឹងក៏ស្លៀកសារុង អ៎! ស្លៀកសំពត់ពណ៌អីខ្មៅអីអ៊ីចឹងទៅ ខ្លះក៏ពណ៌រាងប្រផេះអីអ៊ីចឹងទៅ។ អត់ដូចៗគ្នាទេ។

**ស៖** បាទសូមអរគុណ។ ទាក់ទងទៅនឹងជនជាតិចាវ៉ាយនេះដែរ តើនៅពេលដែលពួកគេចូល មកមានអីវ៉ាន់នៅជាប់មកជាមួយទេ? ហើយលោកស្រី បើមាន លោកស្រីសម្គាល់ថាមានអ្វីខ្លះ ដែលនៅ ជាប់នឹងខ្លួនពួកគេ?

**ឆ៖** អត់មានទេ មានមួយចង្កេះ មួយចង្កេះ។

**ស៖** ចុះគេមានស្ពាយដូចជាសាក់ដូអីដែរទេ?

**ឆ៖** អត់មាន។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សួរបញ្ជាក់អ្នកស្រី មុននេះខ្ញុំស្តាប់មានសំណួរសួរទាក់ទងរឿង ចម្ការខ្នុររួចហើយ។ ខ្ញុំចង់សួរថា អ្នកស្រី នៅពេលដែលអ្នកស្រីស្នាក់នៅក្នុងមន្ទីរអូរកន្សែងហ្នឹង អ្នកស្រី ធ្លាប់មានគេឮ ឬក៏ឮអាការនិយាយគ្នា ឬក៏បានទៅដល់កន្លែងណា ដែលគេហៅថាចម្ការខ្នុរដែរទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញសហមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ ខ្ញុំបានឮសំណួរអំពីចម្ការខ្នុរបីដងហើយ ដែលលោកស្រីបាន និយាយថា គាត់មិនដឹងពីបញ្ហានេះ។ នេះជាសំណួរលើកទី៤ ដែលសួរពីបញ្ហានេះ។ ដូច្នេះខ្ញុំសូមជំទាស់ ចំពោះការលើកសំណួរនេះ។ សូមអរគុណលោកប្រធាន។

[០៩:៥២:២០]

**លោក គង់ សំអុន៖**

បាទ មិនថ្វីទេ បើខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់បែបនេះ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំសូមសួរតទៅទៀត អ្នកស្រីអាចបញ្ជាក់ពីទីតាំងមួយដែលជារណ្តៅគ្រាប់បេ ដែលជាការទម្លាក់គ្រាប់បែកក្នុងសម័យសង្គ្រាម ដែលជារណ្តៅដែលកើតឡើងដោយសារការទម្លាក់គ្រាប់បែកហ្នឹង អ្នកស្រីអាចបញ្ជាក់បានទេ ទីតាំងនៅក្នុងតំបន់ក្បែរមន្ទីរអប់រំអ្វូរកន្សែងហ្នឹង?

**លោកស្រី មឿង ចាន់ឌី៖**

**ឆ៖** ជាប់ពីរណ្តៅហ្នឹង ពីប្រវែង ឬក៏ពីគីឡូអី គឺនាងខ្ញុំអត់បានដឹងទេ។

**ស៖** បាទ សូមអរគុណ។ លោកស្រីធ្លាប់បានឃើញរណ្តៅហ្នឹងញឹកញាប់ដែរឬ ឬក៏ធ្លាប់បានទៅដល់ទីតាំងរណ្តៅហ្នឹងប៉ុន្មានដងដែរ ក្នុងអំឡុងពេលដែលអ្នកស្រីស្នាក់នៅមន្ទីរអ្វូរកន្សែងហ្នឹង?

**ឆ៖** រណ្តៅគ្រាប់បែកហ្នឹង ពេលដែលនាងខ្ញុំទៅបេះបន្លែទៅក៏ឃើញរណ្តៅហ្នឹងជ្រៅ ហើយឬក៏ទៅដកដំឡូងដកអីទៅ ក៏ឃើញ ឃើញរណ្តៅហ្នឹង វាអត់មានលុបដីលុបអីទេ វារណ្តៅជ្រៅតែម្តង រណ្តៅគ្រាប់បែក គឺទម្លាក់ទៅ វា អំា! ទំហំធំដែរ ហើយជ្រៅ បានឃើញ។

**ស៖** បាទ សូមអរគុណ។ ចុះអ្នកស្រីចាំបានទេថា នៅពេលណាដែលរណ្តៅហ្នឹងត្រូវបានលុបដីវិញហ្នឹង?

[០៩:៥៤:៤០]

**ឆ៖** ពេលដែលនាងខ្ញុំទៅមុន ឃើញរណ្តៅហ្នឹងអត់មានលុបដីទេ វាជ្រៅ។ ពេលដែលក្រោយរយៈពេលក្រោយមក នាងខ្ញុំទៅម្តងទៀត រណ្តៅហ្នឹងគេលុបដី។ គេលប់ឡើងដូចថាដីលុបទៅ វាឡើងស្មើ ឬក៏ថាខ្ពស់អីចឹង។ អីចឹងមានអារម្មណ៍ថាខុសប្លែក ពីមុនយើងឃើញជ្រៅ ទៅលើកក្រោយឃើញពេញ។

**ស៖** បាទ សូមអរគុណ។ លោកស្រីអាចបញ្ជាក់បានទេថា មុនពេលដែលលុបដីហ្នឹង លោកស្រីបានទៅកាន់រណ្តៅហ្នឹងប៉ុន្មានដង?

**ឆ៖** ដូចថា ពេលដែលយើងរកបន្លែហ្នឹង ចេះតែឃើញអីចឹង ប៉ុន្តែគ្រាន់ថា យើងមិនទៅជិតរណ្តៅហ្នឹង ឈរក្បែររណ្តៅហ្នឹង ហើយមើលទំហំវាខ្ពស់ទាបអី គឺអត់បានដឹងទេ គ្រាន់ថា ដឹងថាយើងរកក្បែរហ្នឹង វាចម្ងាយឆ្ងាយពីរណ្តៅហ្នឹងដែរ ប៉ុន្តែយើងដឹងថា រណ្តៅហ្នឹងវាជ្រៅ។ ហើយដល់ពេល

ក្រោយទៀត យើងក៏ទៅទៀតទៅ។ ធម្មតាអ៊ីចឹង ជួនអីទៅរកក្បែរៗនុ៎ងទៅ ជួនអីខុសពីកន្លែងរណ្ដៅហ្នឹងមកផ្សេងទៀតមក។ ទៅបានពីរបីដងដែរ ដូចថា ខ្ញុំមិនបានរៀបរាប់ឲ្យបានជាក់ ដូចថា ប៉ុន្មានដងហើយ ខ្ញុំមិនបានចាប់អារម្មណ៍ថា អ្ហ៎!គេឲ្យទៅប្រាំដង ឬ១០ដងអី គឺនាងខ្ញុំអត់បានដឹងទេ។ ដឹងថា ពេលខ្លះហ្នឹងក៏ទៅរក ទៅក្បែរនុ៎ងទៅ ពេលខ្លះក៏អត់ទៅ វាមិនកំណត់ថា ដឹងច្រើនដង វាអត់ដឹងទេ ព្រោះដូចខ្ញុំជម្រាបអ៊ីចឹង ថាមិនបានគិតពិចារណា ប៉ាន់ស្មានអីអ្វីដែលគ្រប់យ៉ាងគឺជិតដល់ទេ ព្រោះបារម្ភតែខ្លាចតែរឿងស្លាប់ ហើយនិងរស់តែប៉ុណ្ណឹង។

[០៩:៥៦:៥១]

**ស៖** បាទសូមអរគុណ។ អ៊ីចឹងតាមសក្ខីកម្មដែលលោកស្រីបានផ្ដល់អម្បាញ់មិញនេះ គឺអ្នកស្រីមិនបានឡើងទៅជាន់ចំពីលើមាត់រណ្ដៅហ្នឹងទេ អ្នកស្រីបានទៅរកបេះបន្លែ គឺនៅឆ្ងាយពីរណ្ដៅហ្នឹង។ តើអ៊ីចឹងទេ? ហើយអ្នកស្រីអាចបញ្ជាក់ពីចម្ងាយបានទេថា អ្នកស្រីដែលចូលកៀកបំផុតនៅក្នុងរណ្ដៅហ្នឹង ពេលណាមួយដែលអ្នកស្រីចូលកៀកបំផុតហ្នឹង ក្នុងចម្ងាយប៉ុនណាដែរ ពីមាត់រណ្ដៅ?

**ឆ៖** នាងខ្ញុំមិនដឹងចម្ងាយប៉ុន្មានម៉ែត្រទេ ដូចថា ប្រៀបដូចថា យើងក្រឡេកទៅៗឃើញអគារនេះឃើញច្បាស់អ៊ីចឹង។ ក្រឡេកទៅឃើញអ៊ីចឹងអ្ហ៎! ហើយបើយើងស្មានថា មិនដឹងប៉ុន្មានម៉ែត្រ ប៉ុន្មានម៉ែត្រ គឺខ្ញុំអត់ដឹងទេ គ្រាន់តែក្រឡេកទៅយើងឃើញច្បាស់តែម្ដង ថាអគារហ្នឹងវាកម្ពស់ណា ហើយឬក៏ថាវាទ្រង់ទ្រាយវា ជញ្ជាំងពីថ្មអីអ៊ីចឹង ឃើញច្បាស់អ៊ីចឹងតែម្ដង។ ដូចយើងប្រៀបដូចអ៊ីចឹង។ ហើយឲ្យទៅឈរលើរណ្ដៅ លើអី នរណាទៅហ៊ានឈរ ខ្លាចខ្មោចផងអីផង ហើយរណ្ដៅនុ៎ង មានប្រេះមានអីអ៊ីចឹង ធុំក្លិនស្អុយ អាណាទៅក្បែរ។

**ស៖** បាទ ខ្ញុំនឹងសួរទៅដល់ចំណុចនេះ ប៉ុន្តែឥឡូវខ្ញុំចង់សួរពីរណ្ដៅដែលលោកស្រីឃើញ មិនទាន់ ដែលលោកស្រីថាមិនទាន់មានលុប។ ខ្ញុំចង់សួរបញ្ជាក់អ្នកស្រី ទាក់ទងទៅនឹងបរិវេណជុំវិញរណ្ដៅហ្នឹង អ្នកស្រីអាចបញ្ជាក់បានទេថា មានអ្វីដែលជាសម្គាល់នៅក្បែររណ្ដៅហ្នឹងបាន?

**ឆ៖** នាងខ្ញុំសម្គាល់ ដឹងចង់សម្គាល់ថាម៉េចផង ព្រោះអីយើងដូចចង់និយាយថា រណ្ដៅនោះវាខ្ទង ហើយដល់ម្ដងទៀតទៅ វាខ្ពស់ដូចជាយើងប្រៀបដូចជាភ្នំអ៊ីចឹង។ យើងមើលអ៊ីចឹង មិនសម្គាល់ថាអ៊ីចឹង។ មួយវាទាប មួយវាខ្ពស់អ៊ីចឹង។ ខ្ញុំសម្គាល់ថា មួយរណ្ដៅជ្រៅ មួយរណ្ដៅគេលុប។

[០៩:៥៩:៤៣]

**ស៖** បាទ សំណួររបស់ខ្ញុំ គឺខ្ញុំចង់សួរអំពីអ្វីដែលអ្នកស្រីអាចសម្គាល់បាននៅក្បែររណ្ដៅហ្នឹង

ឧទាហរណ៍ថា មានដំបូក មានដើមឈើអ្វី ឬដើមឈើអីណាធំ ដែលអាចសម្គាល់ ឬក៏មានអ្វីដែលអាចបញ្ជាក់អំពីទីតាំងជាក់លាក់ដែលរណ្តៅហ្នឹងស្ថិតនៅ ដែលអ្នកស្រីអាចសម្គាល់ថា វាជារណ្តៅហ្នឹង? មានអីដែលលោកស្រីអាចបញ្ជាក់បានទេ? នៅក្បែររណ្តៅហ្នឹង មានអ្វីជាសម្គាល់?

**ឆ៖** នៅក្បែររណ្តៅហ្នឹងអត់មានអីផង មានតែព្រៃ ហើយដើមដំឡូង។

**ស៖** បាទ លោកស្រីអាចរៀបរាប់បន្ថែមទៀត បើអ្នកស្រីចាំ។ លោកស្រីបញ្ជាក់ថា មានព្រៃ និងដើមដំឡូង។ អ្នកស្រីអាចបញ្ជាក់ទេថា បានទេថា ព្រៃដែលលោកស្រីឃើញហ្នឹង នៅចម្ងាយប៉ុន្មានពីរណ្តៅហ្នឹង? ហើយវាមានលក្ខណៈយ៉ាងម៉េចសម្គាល់ទៅលើព្រៃហ្នឹងដែរ ថាវាជាប្រភេទដើមឈើស៊ុបទ្រុប ឬវាគ្រាន់តែជាដើមឈើ ជាព្រៃរបោះ មួយដើម មួយដើមទេ អ្នកស្រីអាចបញ្ជាក់បានទេ?

**ឆ៖** យើងក្រឡេកទៅមើលពីចម្ងាយអ៊ីចឹង ប្រហែលជាព្រៃស៊ុបទ្រុប មិនដឹងជាដើមអីខ្លះ យើងក៏មិនបានចាប់អារម្មណ៍ថា ដើមអីៗ ហើយងាកទៅ ដូចថាជុំវិញរណ្តៅហ្នឹងមានកន្លែងខ្លះ ក៏ដើមឈើរង្វើលៗអ៊ីចឹងទៅ។ កន្លែងខ្លះក៏វាព្រៃស៊ុបទ្រុប ដូចជាដើមធំៗអីអ៊ីចឹងទៅ។

**ស៖** បាទ សូមអរគុណ។ នៅជុំវិញរណ្តៅហ្នឹងដែលអ្នកស្រីថា ជាព្រៃមានរង្វើលផង មានស៊ុបទ្រុបផង អ្នកស្រីអាចសម្គាល់បានពីប្រភេទដើមឈើដែលដុះនៅក្បែររណ្តៅហ្នឹងបានទេ? ជាប្រភេទឈើយ៉ាងម៉េច បើសិនជាអ្នកស្រីមិនស្គាល់ឈ្មោះដើមឈើទេ អាចបញ្ជាក់ថា វាជាឈើ ដើមឈើព្រៃ ឬក៏ដើមឈើស្រុក ដែលគេដាំជាដំណាំហូបផ្លែ?

[១០:០២:៥០]

**ឆ៖** ដើមឈើខ្លះប្រហែលជាគេហូបផ្លែដែរ យើង ដូចថាយើងមើលពីចម្ងាយអ៊ីចឹងទៅណា ហើយដើមឈើខ្លះ អ៊ូ! យើងមិនបានប៉ាន់ស្មានថា ដើមឈើអីខ្លះផង។ របៀបដូចថា យើងមើលពីចម្ងាយប្រហែលជាឆ្ងាយល្មមដែរ យើងមើលថា ម៉ា! ដូចជាភូមិអ៊ីចឹង ដូចជាដើមឈើរបៀបដូចជាភូមិ ឬក៏ថាដូចជាយើងដាំស្អី បើថាយើង ដីយើង គឺយើងដាំជាចម្ការអីអ៊ីចឹង ដូចអ៊ីចឹង ម្យ៉ាង។ ហើយម្យ៉ាងទៀតទៅដូចជាដើមឈើល្បាស់ៗអីអ៊ីចឹងទៅ យើងអត់បានស្មានអ៊ីចឹង។ ប៉ុន្តែបើឲ្យខ្ញុំស្មាន គឺមានខុស ហើយនិងត្រូវខ្លះ ការស្មានរបស់ខ្ញុំ។ អាហ្នឹងខ្ញុំក្រឡេក ដូចថាយើងមើលពីចម្ងាយទៅ វាមានព្រៃស៊ុបទ្រុប ហើយដូចជាៗដំណាំដូចក្នុងភូមិយើងអ៊ីចឹងដែរ។

**ស៖** បាទ សូមអរគុណ។ មុននេះអ្នកស្រីបញ្ជាក់អំពីដំឡូងដែលនៅក្បែរហ្នឹង។ អ្នកស្រីអាចបញ្ជាក់បានទេថា ដំឡូងហ្នឹងដំឡូងអី? ហើយវាមានចម្ងាយប៉ុន្មានពីរណ្តៅដែរ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** គេដាំដំឡូងហ្នឹង ខាង ប្រហែលជាខាងអ្នកគុកបឹងកន្សែងហ្នឹងដាំ អត់មានប្រជាជនមកដាំទេដំឡូង ដូចថាដាំជុំវិញរណ្ដៅហ្នឹង ព្រោះអីខ្ញុំទៅឃើញ ជួនអីមានដើមដំឡូងហ្នឹង នៅជិតៗរណ្ដៅហ្នឹងដែរ។ មានដើមឈើ ដើមដំឡូងអីអឺចឹងទៅ ហើយមានអាព្រៃល្បាស់ៗ គេហៅ ជនជាតិគេហៅ ស្លឹកកណ្ដេវអីហ្នឹង។ យើងទៅបេះអាស្លឹកកណ្ដេវ ស្លឹកអីហ្នឹង ស្ងហ្នឹង។

**ស៖** បាទ អ្នកស្រីអាចចាំថា ជាដំឡូងអីទេ?

**ឆ៖** ជាដំឡូងឈើ។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីអាចបញ្ជាក់ពីទំហំដើមរបស់វា កម្ពស់របស់វាប៉ុន្មានដែរ ពេលដែលអ្នកស្រីឃើញហ្នឹង?

**ឆ៖** ដើមដំឡូងប៉ុនៗ អើយ! ខ្ញុំមិនចេះស្មានទេ បើថាអ្នកដែលស្គាល់ដើមដំឡូងបានចេះប្រាប់ប្រាប់ទៅអាចយល់ ដល់អ្នកអត់ស្គាល់ដើមដំឡូង ដល់ប្រាប់ទៅក៏មិនយល់ដដែលហ្នឹង។

[១០:០៦:០៨]

**ស៖** បាទ សំណួររបស់ខ្ញុំសួរពីទំហំ ហើយនិងកម្ពស់។ អ្នកស្រីអាចបញ្ជាក់មើល ដំឡូងឈើដែលអ្នកស្រីចូលទៅហ្នឹងងវាលិចផុតក្បាលអ្នកស្រី ឬមួយក៏វាដុះទាបៗទេ?

**ឆ៖** ដើមដំឡូងវាខ្ពស់ៗជាងក្បាលខ្ញុំបន្តិច។

**ស៖** ច្រើនប៉ុនណាដែរអ្នកស្រី អាចបញ្ជាក់បានទេ?

**ឆ៖** ដើមដំឡូងតែគេដាំហើយចំនួនច្រើនហើយ មិនដែលដាំមួយដើមពីរដើមទេ។ មួយដើមពីរដើមទាល់តែនៅក្នុងផ្ទះ ឬក្នុងជាប់ផ្ទះយើង។ អាហ្នឹងគេដាំច្រើនហើយ ដីធំទូលំទូលាយ គេដាំច្រើន។

**ស៖** បាទ សូមអរគុណ។ លោកស្រីអាចបញ្ជាក់ទីតាំងដើមដំឡូងហ្នឹងបានទេ បើធៀបទៅនឹងរណ្ដៅគ្រាប់ហ្នឹង ថាតើវានៅខាងលិច ខាងជើង ខាងត្បូង នៅទិសខាងណាមួយ?

**ឆ៖** នាងខ្ញុំមិនបានចាប់អារម្មណ៍ថា ទិសណាទេ។ ដឹងថាក្បែររណ្ដៅមានដើមដំឡូង មានដើមព្រៃឈើជុំវិញតែប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ ឥឡូវយើងនិយាយពីពេលដែលលោកស្រីថា ឃើញរណ្ដៅបេហ្នឹងត្រូវបានគេលុបដី។ អ្នកស្រីអាចបញ្ជាក់បានទេថា អ្វីដែលជាការសម្គាល់របស់អ្នកស្រីថា រណ្ដៅមួយដែលមិនមានលុបដី ហើយនិងរណ្ដៅទី២ រណ្ដៅមួយទៀតដែលអ្នកស្រីថា ឃើញលុបដីហ្នឹងវាជារណ្ដៅតែមួយ អ្នកស្រីមានអីបញ្ជាក់?

[១០:០៨:២៤]

**ឆ៖** រណ្ដៅមានតែមួយ ពេលដែលនាងខ្ញុំទៅឃើញរណ្ដៅខូង ពេលដែលទៅម្ដងទៀត ឃើញរណ្ដៅលុបដី ហ្នឹងនាងខ្ញុំឃើញអ៊ីចឹង ដឹងបញ្ជាក់ថាម៉េចទៀត។

**ស៖** អ្នកស្រីអាចចាំ ឧទាហរណ៍ថា ប្រភេទដើមឈើដែលដុះនៅលើរណ្ដៅហ្នឹងមុនពេលលុបដី ហើយនិងពេលលុបដីហ្នឹង វាជាប្រភេទដើមឈើប្រភេទព្រៃ ឬប្រភេទដំឡូងអីតែមួយដូចគ្នាក្នុងពេលដែលអ្នកស្រីឃើញមុន ហើយនិងក្រោយពេលលុបដីហ្នឹងដែរទេ?

**ឆ៖** ពេលរណ្ដៅហ្នឹងក៏ឃើញរណ្ដៅហ្នឹងមុន មិនទាន់មានដើមដំឡូង ដើមអីទៀតទេ យូរបន្តិចទៅបានមានដើមដំឡូងដើមអីដុះ។

**ស៖** បាទ អ៊ីចឹងខ្ញុំចង់បញ្ជាក់អ្នកស្រី នៅពេលដែលលោកស្រីឃើញរណ្ដៅហ្នឹងដំបូង មិនមានដើមដំឡូងទេ តែនៅពេលដែលអ្នកស្រីថា ឃើញពេលលុបដីនេះ បានអ្នកស្រីប្រទះឃើញដើមដំឡូង។ តើអ៊ីចឹងមែនទេ?

**ឆ៖** ពេលទៅក្រោយហើយ ឃើញលុបដីលុបអីហើយ មានដើមដំឡូងដើមអីហ្នឹង។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីអាចបញ្ជាក់ទេថា ដំឡូងដែលអ្នកស្រីឃើញហ្នឹងជាការដាំលើកជារង ជាជួរ ឬមួយក៏ដាំនៅក្នុងលើដីស្មើ ដោយមិនមានការលើកជារងទេ?

[១០:១០:៣៧]

**ឆ៖** នាងខ្ញុំសូមបញ្ជាក់ម្ដងទៀត។ ដើមដំឡូងហ្នឹង នៅឆ្ងាយពីរណ្ដៅដែលយើងក្រឡេកទៅឃើញដាំខាងឆ្វេង អ៊ីចឹងទៅឃើញដើមដំឡូង។ ហើយដើមឈើយើងក្រឡេកទៅមុខទៅ ឃើញដើមឈើ។ ហើយក្រឡេកមកក្រោយ ឃើញដើមឈើល្បាស់ៗ។ អាហ្នឹងមិនមែនជា ដូចថា យើងពេលដែលយើងឃើញរណ្ដៅហ្នឹង ក៏វាមានផ្សំនឹងដើមដំឡូងអី គេដាំនៅខាងៗ ឆ្ងាយៗពីដូចថាយើងប្រៀបដូចថាពីផ្ទះយើងអ៊ីចឹង។ យើងដាំដំណាំផ្សេងឲ្យឆ្ងាយពីៗផ្ទះយើងអ៊ីចឹងដែរ។ ហ្នឹងខ្ញុំចង់និយាយថាឲ្យច្បាស់ថាអ៊ីចឹង។ ព្រោះពេលដែលខ្ញុំទៅឃើញហ្នឹង ក៏មិនមែនថាដំឡូងហ្នឹងអត់មានអត់អីទេ ឃើញរណ្ដៅ ក៏ឃើញដំឡូង ខាងឆ្វេងខាងស្ដាំងអីអ៊ីចឹងទៅ។ ប៉ុន្តែវាមិនអាចនៅជិតនឹងមាត់រណ្ដៅហ្នឹងទេ គឺវានៅរយៈពេលឆ្ងាយដែរ ដូចថាជាដីឡូរបស់យើងអ៊ីចឹង យើងដាំឲ្យឆ្ងាយពីផ្ទះយើងអ៊ីចឹង ប្រៀបអ៊ីចឹង។

**ស៖** អ្នកស្រីសំណួររបស់ខ្ញុំ ខ្ញុំសួរថាតើដំឡូងហ្នឹងដាំដោយលើករង ឬមួយក៏ដាំលើដីស្មើ? អ្នកស្រីអាចសម្គាល់បានទេនៅពេលនុ៎ង?

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ដំឡូងគេដាំនៅចម្ការហ្នឹង មិនដឹងជាលើករង មិនដឹងជាស្មើអីទេ។ អាហ្នឹងដូចជាអត់ ដូចជាមិនបញ្ហាទេ អាដាំដំឡូងហ្នឹង។ បើតែថាតាមការពិត គឺចម្ការគេៗចេះតែដាំៗទៅ។ ខ្ញុំមិនបានទៅចាប់អារម្មណ៍ថារង ជារង ជាស្មើអីទេ គឺអត់ដឹងទេ។

[១០:១២:៣៤]

**ប្រធានអង្គជំនុំ៖**

អស់ពេលហើយលោកមេធាវី។ បាទ ឥឡូវអង្គជំនុំជម្រះសូមអរគុណលោកស្រី មឿង ចាន់ឌី។ សវនាការស្តាប់សក្ខីកម្មរបស់លោកស្រីក្នុងឋានៈជាសាក្សី បានដល់ទីបញ្ចប់ហើយ ហើយសក្ខីកម្មរបស់លោកស្រីនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តី។ វត្តមានរបស់លោកស្រីនៅអ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ។ លោកស្រីអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកស្រីមានបំណងចង់ទៅបានហើយ។ សូមលោកស្រីមានសុខភាពល្អ ជួបតែសំណាងល្អ និងបានសេចក្តីសុខសេចក្តី សេចក្តីចម្រើន។ ហើយអង្គជំនុំជម្រះក៏សូមអរគុណលោកស្រី ស៊ុន សូលីដា បុគ្គលិកអង្គការ ធី.ភី.អូ ដែលបានជួយគាំទ្រដល់កិច្ចដំណើរការសវនាការស្តាប់សក្ខីកម្មសាក្សីរូបនេះ ដែលចូលរួមតាមសំណើសុំរបស់សាក្សី។ ឥឡូវនេះលោកស្រីអាចសម្រាកបានហើយ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោកស្រី មឿង ចាន់ឌី វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬគោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

ហើយអង្គជំនុំជម្រះសូមជម្រាបថា នៅក្រោយពេលសវនាការស្តាប់សក្ខីកម្មសាក្សីរូបនេះ អង្គជំនុំជម្រះនឹងសវនាការស្តាប់សារណាភាគី ផ្ទាល់មាត់របស់ភាគីពាក់ពន្ធអំពីសំណើរបស់សហមេធាវីការពារក្តីទាំងពីរក្រុម ដែលបានដាក់ឯកសារថ្មីៗសុំមកអង្គជំនុំជម្រះសូមឱ្យទទួលយកធ្វើជាភស្តុតាងសួរដេញដោលអ្នកជំនាញដែលមានរហស្សនាម 2-TCE-88។ សូមភាគីជ្រាប។

ឥឡូវនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៤នាទី ដល់ម៉ោង ១០:៣៥ នាទី)*

[១០:៣៥:៣២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះធ្វើសវនាការស្ដាប់សារណាផ្ទាល់មាត់របស់ភាគី ទៅលើសំណើសុំរបស់ក្រុមសហមេធាវីការពារក្ដី នួន ជា និងសហមេធាវីការពារក្ដី ខៀវ សំផន ដែលបានស្នើសុំឱ្យអង្គជំនុំជម្រះទទួលយកឯកសារចំនួន១៧ និងចំនួនប្រាំមួយផ្សេងគ្នា អនុលោមតាមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុងសម្រាប់ជាមូលដ្ឋាន សំអាងក្នុងការសួរដេញដោលអ្នកជំនាញ ដែលមានរហស្សនាម 2-TCE-88 ដែលអង្គជំនុំជម្រះគ្រោងកោះហៅឱ្យមកផ្ដល់សក្ខីកម្មចាប់ពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ (ឯកសារ E387, E387/1)។

ហើយកាលពីថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងបានជម្រាបជូនដំណឹងដល់ភាគីថា អង្គជំនុំជម្រះមានបំណងស្ដាប់នូវសារណាផ្ទាល់មាត់របស់ភាគីនានាពាក់ព័ន្ធ ប្រសិនបើមាន បន្ទាប់ពីស្ដាប់សក្ខីកម្មសាក្សី មឿង ចាន់ឌី បានចប់។ ឥឡូវនេះយើងបានចប់ហើយ។ អ៊ីចឹងជាបន្តទៅនេះអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅសហតំណាងសហព្រះរាជអាជ្ញា ដើម្បីធ្វើការឆ្លើយតបទៅនឹងសំណើសុំរបស់ក្រុមសហមេធាវីការពារក្ដី នួន ជា និង ខៀវ សំផន ទៅតាមលំដាប់លំដោយនៃសំណើសុំដែលបានជូន ជម្រាបជូនរួចហើយ។ សូមអញ្ជើញ!

[១០:៣៧:២១]

**លោក វីណ្ឌៀម ស្មីត៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ សូមជម្រាបសួរលោកមេធាវី។ យើងបានទទួលនូវសេចក្ដីសម្រេច <87.4 ស្នើសុំឯកសារនានា ដើម្បីប្រើប្រាស់ជាមួយ អាឡិចហ៊ីនតុន -- សុំទោស គឺ TCE-88។ នោះគឺឯកសារ E387 និង E387/1។> ពាក់ព័ន្ធទៅនឹងឯកសាររបស់ ខៀវ សំផន យើងមិនមានការជំទាស់ក្នុងការទទួលយកឡើយ។ <ពួកគេបានស្នើសុំដាក់>ឯកសារប្រាំ<> ទី១ គឺប្រវត្តិរូប។ ខ្ញុំគិតថា ជាគំនិតល្អដែលមានប្រវត្តិរូបនេះ។ ហើយឯកសារមួយទៀត គឺជាឯកសារសរសេររបស់អ្នកជំនាញ <និង>បញ្ហា<ទូទៅ>ដែល<គាត់នឹងផ្ដល់សក្ខីកម្ម>។ ហើយនិងមួយទៀតគឺពាក់ព័ន្ធទៅនឹង<ការរិះគន់>សៀវភៅរបស់<គាត់ ដោយ>ហង់រី ឡូកា។ ហើយ<ការរិះគន់>ទាំងអស់

នេះ គឺវាជា<សំបុត្រផ្ញើទៅ>ភ្នំពេញប៉ុស្តិ៍ <ក៏ដូចគ្នាទៅនឹងអ្វីមួយចំនួន>ដែលសាក្សីអ្នកជំនាញបានផ្តល់ជូន។ ហើយនៅក្នុងឯកសារនេះ គឺមានមូលដ្ឋានអង្គហេតុមួយចំនួនដែលគេបានលើកឡើង ដើម្បីឲ្យមានការពិភាក្សា<ពាក់ព័ន្ធនឹង>ការរិះគន់<សៀវភៅរបស់គាត់>។

ទាក់ទងនឹងតម្លៃនៃភ័ស្តុតាង យើងសូមលើកឡើងថា ឯកសារដែលយើងប្រើជាមួយសាក្សីនេះ គឺវាមានតម្លៃភ័ស្តុតាងខុសគ្នាបន្តិចបន្តួច គឺឯកសារដែលមានលក្ខណៈជាឯកសារឯករាជ្យ ហើយមិនចាំបាច់ត្រូវប្រើប្រាស់សម្រាប់ការសួរដេញដោលនោះឡើយ។ ខ្ញុំគិតថា តម្លៃនៃឯកសារនុំង គឺនឹងបង្ហាញនៅពេលដែលយើងលើកយកមកពិភាក្សាដេញដោលនៅក្នុងសាលសវនាការនេះ។

[១០:៣៨:២១]

ពាក់ព័ន្ធទៅនឹងសំណើរបស់ នួន ជា វិញ គឺគេស្នើសុំដាក់ឯកសារ១៧ ហើយក្រៅពីឯកសារចំនួនពីរដែល<យើងជំទាស់> ខ្ញុំយល់ស្របថា ឯកសារ១៥ គួរអាចមានប្រយោជន៍។ ជាពិសេស ឯកសារទាំងអស់នោះអាចប្រើប្រាស់ជាមួយសាក្សី គឺសាក្សីអ្នកជំនាញ។ ឯកសារពីរដែលយើង <សូមទោស> ក្នុងចំណោមឯកសារទាំង១៥ ដែលយើងយល់ស្របនុំង <>ភាគច្រើន គឺជាឯកសារដែលសរសេរដោយអ្នកជំនាញ ឬក៏ឯកសារអំពីអ្នកជំនាញ។ <ជាជីវប្រវត្តិលម្អិតរបស់គាត់> ជាសេចក្តីសង្ខេបទៅលើអ្វីដែលគាត់ធ្វើ អ្វីដែលគាត់សរសេរក្នុងការងាររបស់គាត់ ក៏ដូចជាឯកសារនៅតាមវេបសាយនានា ខ្ញុំគិតថា ឯកសារទាំងអស់នេះ គឺមានប្រយោជន៍។

ចំណែកឯកសារដែលបានស្នើសុំ ហើយដែលបានលើកឡើងប្រហែល<ជាពាក់ព័ន្ធបន្តិចថែមទៀតជាមួយ>នឹង ខៀវ សំផន <និងពាក់ព័ន្ធទៅនឹងការតតាំងគ្នា ឬការដេញដោលគ្នា>អំពី<ថាតើ> អំពើប្រល័យពូជសាសន៍<>កើតឡើងនៅកម្ពុជា<ឬក៏អត់ទេ>។ ហើយដូចដែលលោក លោកស្រីចៅក្រមបានសម្រេចក្នុងឯកសារ <> E388 គឺនិយាយទាក់ទងទៅនឹងអ្នកជំនាញ។ បញ្ហានៃអំពើប្រល័យពូជសាសន៍ គឺជាបញ្ហារបស់អង្គជំនុំជម្រះ ហើយវាមិនមែនជាបញ្ហារបស់អ្នកជំនាញ ឬក៏សាក្សីដែលមកបង្ហាញនៅទីនេះឡើយ។

អ្វីដែលអង្គជំនុំជម្រះបាននិយាយ គឺថាមូលដ្ឋានអង្គហេតុដែលនាំទៅដល់ការទាញសេចក្តីសន្និដ្ឋានមួយនេះ គឺអាចជួយដល់អង្គជំនុំជម្រះ ក៏ដូចជាលោក លោកស្រីចៅក្រមក្នុងការចេញសេចក្តីសម្រេច។ <ដូចបានបញ្ជាក់មក>ហើយ ទើបយើងទទួលយក<ឲ្យដាក់ឯកសារទាំងនោះ>។

[១០:៤១:២២]

ចំណែកឯកសារពីរទៀត ដែលខាងក្រុម នួន ជា ស្នើសុំដាក់ចូលទៅក្នុងសំណុំរឿង <ដោយជាប់ពាក់ព័ន្ធទៅនឹងអ្នកជំនាញ>នោះ គឺឯកសារ <E387.1.14> <ហើយនោះ>គឺជា<អត្ថបទមួយដែលមានចំណងជើងថា៖ "បញ្ហានៃការរៀបចំច្បាប់អន្តរជាតិ: តើមាន>អំពើសាហាវយង់ឃ្នងក្នុងប្រទេសកម្ពុជា <និងអំពើប្រល័យពូជសាសន៍នៅកូសូវ៉ូទេ?"> ដែលសរសេរដោយ វីល្លៀម <ស្កាបាស> ដែលជាអ្នកនិពន្ធដ៏ល្បីមួយរូប។ ហើយយើងជំទាស់ទៅនឹង<ការដាក់>ឯកសារនេះ ដោយផ្អែកលើមូលដ្ឋានថា<> <តើមាន>អំពើប្រល័យពូជសាសន៍<បានកើតឡើងទេ? ហើយនេះជាសំណួរសម្រាប់លោក លោកស្រីចៅក្រម>។ <លុះណាតែអត្ថបទនៃ>ឯកសារមួយនេះ <នាំមកនូវមូលដ្ឋានអង្គហេតុសំខាន់មួយចំនួន>គាំទ្រដល់ការអះអាង<របស់លោក លោកស្រីចៅក្រម> ហើយយើងអាចនឹងពិភាក្សាទៅលើបញ្ហានេះនៅពេលក្រោយ។ ប៉ុន្តែខ្ញុំគិតថា ឯកសារនេះវាមិនបានជួយដល់អង្គជំនុំជម្រះក្នុងការស្វែងរកការពិតឡើយ។ ប្រសិនបើលោក លោកស្រីចៅក្រមពិនិត្យទៅលើអត្ថបទនេះ គឺថាវាជាអត្ថបទមួយដែលលើកឡើងនៅក្នុងការពិភាក្សាដេញដោល<> ដែលអង្គហេតុសំខាន់មិនត្រូវបានលើកយកមកពិភាក្សានោះឡើយ។ <សូម្បីតែនៅទំព័រទី១ នៃ>ឯកសារនេះ មិនមានការពិភាក្សាលម្អិតណាមួយអំពីអង្គហេតុដើម្បីគាំទ្រទៅដល់គំនិតដែលថា <"តាមពិតទៅ កេរ្តិ៍ឈ្មោះមិនល្អនៃការជម្លៀសប្រជាពលរដ្ឋចេញ>ទីក្រុងនានានៃប្រទេសកម្ពុជា គឺ<បានបង្ហាញឲ្យឃើញ>នៅពេលដែលចាប់ផ្តើម<>បដិវត្តន៍សង្គមនិយមដ៏ចម្លែករបស់ប្រទេសនេះ ហើយបដិវត្តន៍នោះសម្រេចដោយជោគជ័យ ដោយសន្តិភាព<">។ <ជាក់ស្តែងណាស់ គឺយើងដាក់បញ្ចូល មិនមែន>ស្របជាមួយនឹងភ័ស្តុតាង<ទេ>។ ដូច្នេះខ្ញុំសូមបញ្ជាក់ថា យើងមិនគាំទ្រដល់ការទទួលយកឡើយ ដោយសារមតិទាំងអស់នេះ វាមិនផ្អែកទៅលើអង្គហេតុឡើយ។

[១០:៤៣:១៩]

ឯកសារមួយទៀតគឺ<ដែលយើងជំទាស់ គឺ> <E387.1.16> គឺជាមតិរបស់អ្នកនិពន្ធដែលផ្ញើ<ទៅ>កាសែតញូវយ៉កថាមស៍ ហើយមានការថ្លែង<ពីការព្រួយបារម្ភ>របស់គាត់<នៅ>ឆ្នាំ២០០៨<អំពី>ភាពឯករាជ្យនៃតុលាការនៅកម្ពុជា ដែល<ត្រូវបានបង្កើតជា> អ.វ.ត.ក ផងដែរ។ <ចំណុចទី១ ដែលយើងជំទាស់ គឺ>ថាបញ្ហានេះ មិនមែនជាបញ្ហាដែលសាក្សីត្រូវផ្តល់សក្ខីកម្មនោះឡើយ។ ហើយទី២ គឺថាអង្គសេចក្តីរបស់ឯកសារនេះ គឺវា<កើតឡើង>ខុស<ពេលវេលា>គ្នា<ឆ្ងាយ។ វាមានភាពមិនច្បាស់លាស់ អំពី>ភាពពាក់ព័ន្ធផ្ទាល់ជាមួយការជំនុំជម្រះនេះឡើយ។ ហើយ<វាពិតជាកើត>ឡើង

<យូរមកហើយ មុនបញ្ហានៃការវិវាទជាលក្ខណៈផ្លូវច្បាប់នេះ ដែលបញ្ហាទាំងនេះ និងបញ្ហាផ្សេងៗទៀត ត្រូវបានគេពិភាក្សាអំពីភាពមិនលម្អៀង ជាពិសេសនៅក្នុងអង្គជំនុំជម្រះនេះ>។ ដូច្នេះខ្ញុំសូមលើកឡើងថា ឯកសារនេះ គឺមានតម្លៃភ័ស្តុតាងតិចតួចបំផុតដែលអាចមើលរំលងបាន <ហើយយើងសូមជំទាស់នូវការទទួលយកឯកសារនេះ>។

បាទ ខ្ញុំសូមបញ្ចប់ការលើកឡើងរបស់យើងខ្ញុំ។ សូមអរគុណអង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

បាទ តទៅនេះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ យើងខ្ញុំ <នឹង>គោរពទៅតាមការសម្រេចរបស់អង្គជំនុំជម្រះ ពាក់ព័ន្ធទៅនឹងឯកសារទាំងអស់ដែលបានស្នើសុំដោយមេធាវីការពារក្តីលោក ខៀវ សំផន និងលោក នួន ជា។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៀតអង្គជំនុំជម្រះ -- សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១០:៤៥:២៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានការកត់សម្គាល់មួយ។ ខ្ញុំសង្កេតឃើញថា នៅក្នុងឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធនៃសំណើរបស់ នួន ជា <>ដូចជា<មិនត្រូវបានបង្ហាញតាមលំដាប់លំដោយទេ។> <>ឯកសារ<លេខ>២ និងឯកសារលេខ៣<> លើកលែងតែខ្ញុំភ័ន្តច្រឡំ គឺ<បង់លេខខុស។ នោះគឺឯកសារលេខ ២ មានលេខ> E387.1.3 <ផ្ទុយទៅវិញ នេះគឺជា>ឯកសារលេខ៣<>។ <>ឯកសារលេខ១៤, ១៥ ក៏មានលេខរៀងបញ្ច្រាសគ្នាដែរ។ អ៊ីចឹងសូម<ឲ្យក្រុមមេធាវីការពារក្តីលោក នួន ជា>ពិនិត្យមើលឯកសារហ្នឹងឡើងវិញថា តើការចុះលេខរៀងហ្នឹង វាត្រឹមត្រូវឬក៏អត់។ <បើមិនត្រឹមត្រូវទេ> សូមឲ្យមេធាវីការពារក្តីដាក់សំណើសុំដើម្បីកែប្រែឡើងវិញ<>។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ពាក់ព័ន្ធទៅនឹងមតិរបស់ចៅក្រម ឡាវែន៍ ខ្ញុំសូមបញ្ជាក់ថា <បើសិនជាមាន>ការប្រើប្រាស់លេខ<ខុស> <>ខ្ញុំនឹង<ដាក់ពាក្យសុំជាថ្មីទៀតនៅ>ឆាប់ៗនេះតាមដែលអាចធ្វើបាន គឺប្រហែលជានៅក្នុងថ្ងៃនេះ។

[១០:៤៧:៣០]

ឥឡូវនេះ ខ្ញុំសូមឆ្លើយតបទៅនឹងការលើកឡើងរបស់ព្រះរាជាអាជ្ញា។ ខ្ញុំសូមឆ្លើយតបដោយខ្លី ព្រោះថា ក្នុងចំណោមឯកសារ១៧ ដែលបានស្នើសុំឲ្យដាក់ចូលជាភ័ស្តុតាងនោះ ខ្ញុំគិតថា ជាមតិទូទៅមួយ គឺថាវាអាចមានឯកសារមួយឬក៏ពីរ ដែលមាននៅក្នុងសំណុំរឿងទាក់ទងទៅនឹងលោក ហ៊ីនតុន <គឺមិនច្រើនទេនៅពេលនេះនៅក្នុងសំណុំរឿង>។ ភាគច្រើន<>សៀវភៅរបស់គាត់<មានតែ> <"> ហេតុអ្វីបានជាគេសម្លាប់<?"> ជាដើម។ ដូច្នេះខ្ញុំគិតថា <វាមានភាព>ចំបាច់ក្នុងការពង្រឹកទំហំនៃភ័ស្តុតាង<ដែលផ្តល់ឲ្យដោយ>លោក ហ៊ីនតុន <ដែលជាអ្នកជំនាញនេះ>។ ឯកសាររបស់យើងគឺមានជាបីប្រភេទសំខាន់ៗ។ ឯកសារបី ពាក់ព័ន្ធទៅនឹងប្រវត្តិរូបរបស់គាត់ ក៏ដូចជាវិធីសាស្ត្រក្នុងការស្រាវជ្រាវរបស់គាត់។ ឯកសារប្រាំបួនទៀត គឺពាក់ព័ន្ធទៅនឹង<កង្វះអព្យាក្រឹតភាព និងភាពមិនលម្អៀងរបស់>អ្នកនិពន្ធ និង<>ឯកសារទូទៅ <ដែលក្នុងនោះមាន>ឯកសារ<ពីរ>ដែលព្រះរាជអាជ្ញាបានលើកឡើងនោះ។

ខ្ញុំសូមបញ្ជាក់ថា ឯកសារពាក់កណ្តាល គឺមិនអាចរកបាននៅមុនពេលចាប់ផ្តើមសវនាការនេះ។ ហើយឯកសារខ្លះទៀត គឺត្រូវបានរកឃើញក្រោយពេលដែលអង្គជំនុំជម្រះចេញសេចក្តីសម្រេចលើវិសាលភាព<នៃជំនាញការរបស់អ្នកជំនាញនេះ>គឺនៅថ្ងៃ<ទី២៤> នៅខែកុម្ភៈ ឆ្នាំ២០១៦នេះ<>។ ខ្ញុំគិតថាភាគីទាំងអស់យល់ស្របទាំងអស់គ្នាថា មិនមែនអ្នកជំនាញទេជាអ្នកសម្រេច ថាតើមានអំពើប្រល័យពូជសាសន៍កើតឡើងឬក៏អត់នោះ គឺកាលចន្លោះឆ្នាំ៧៥ ដល់៧៩នោះ។ ហើយប្រាកដណាស់ថានេះគឺជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង។ <ទោះបីជាយ៉ាងណា អ្នកជំនាញមិនដូច>មនុស្ស<ធម្មតាទេ។> <ទោះបីជាមិនមែនជា>អ្នកច្បាប់ <ក៏គាត់>បានចូលរួមពិភាក្សាទាក់ទងទៅនឹងបញ្ហាអំពើប្រល័យពូជសាសន៍។ <ជាការពិត> អង្គជំនុំជម្រះសាលាដំបូងខ្លួនឯងផ្ទាល់ ក៏បានពិចារណាផងដែរនៅក្នុងសេចក្តីសម្រេច <>388 ដែលមានម្តង<អ្នកជំនាញគឺជាប្រធានសមាគមអន្តរជាតិនៃអ្នកស្រាវជ្រាវបទប្រល័យពូជសាសន៍> ហើយក៏<មានតំណែង>នៅក្នុងគណៈកម្មការយូនីស្កូ ទាក់ទងទៅនឹងការប្រឆាំងអំពើប្រល័យពូជសាសន៍។ ដូច្នេះខ្ញុំគិតថា <ភាគីទាំងអស់>នឹងមិនសួរសំណួរ<ទៅអ្នក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01215614



ជំនាញអំពីនិយមន័យ>ច្បាប់<>។

[១០:៥០:៥៨]

ដូច្នេះខ្ញុំគិតថា <>ឯកសារ<របស់អ្នកជំនាញ ស្កាបាស> ពាក់ព័ន្ធទៅនឹង<សំណួរថាតើវប្បធម៌>ប្រល័យពូជសាសន៍<មានចែងក្នុងព្រំដែននៃអនុសញ្ញាបទឧក្រិដ្ឋប្រល័យពូជសាសន៍ឬទេ> គួរតែទទួលយក <ព្រោះអ្នកជំនាញនេះបានតតាំងនឹងសញ្ញាណនេះ។> ហើយខ្ញុំគិតថា យើងមិនមែនធ្វើនេះដើម្បីជជែកសួរដេញដោលជាមួយអ្នកជំនាញដែរ ប៉ុន្តែវាគ្រាន់តែ<>ជាប្រវត្តិមូលដ្ឋាន<យោងទៅលើតួនាទីរបស់គាត់ ដែលគាត់បានទទួល>តែប៉ុណ្ណោះ។

ខ្ញុំយល់ថា ការជំទាស់របស់ព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងឯកសារទី២ គឺប្រាកដណាស់ <>យើង<>នឹងមិនសួរសំណួរ<អ្នកជំនាញ>ទាក់ទងទៅនឹង<បញ្ហា>យុត្តាធិការ ទាំងយុត្តាធិការបុគ្គល <ក្រោមកំហិតនៃពេលវេលា ឬបញ្ហាថាតើ>ការជំនុំជម្រះ<ក្ដីដោយយុត្តិធម៌នៅក្នុងស្ថាប័ននេះអាចធ្វើទៅរួចឬក៏អត់>នោះឡើយ។ ហើយអង្គហេតុជំនុំជម្រះក៏ដឹងច្បាស់អំពីគោលជំហររបស់យើងទៅលើចំណុចទាំងអស់នេះ។ ខ្ញុំគិតនេះ វា<>គ្រាន់តែជាមូលដ្ឋានដើម្បីឲ្យមានការយល់ដឹងឲ្យបានលម្អិតបន្ថែមទៀតទាក់ទងទៅនឹងគោលជំហររបស់អ្នកជំនាញតែប៉ុណ្ណោះ។ ខ្ញុំគិតថា នេះគឺជាមូលដ្ឋាននៃឯកសារពីរដែលព្រះរាជអាជ្ញាបានជំទាស់។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ ចុងក្រោយផ្ដល់វេទិកាជូនទៅសហមេធាវីការពារក្ដីលោក ខៀវ សំផន។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ដូចតាមការស្ដាប់របស់សហព្រះរាជអាជ្ញាអម្បាញ់មិញនេះ លោកមិនមានការជំទាស់ចំពោះឯកសាររបស់យើងទេ។ ដូច្នេះខ្ញុំមិនមានអ្វីនឹងឆ្លើយតបទេ។ ហើយដោយឡែកទាក់ទងនឹងការដាក់ឯកសាររបស់ខាងក្រុម នួន ជា ខាងយើងខ្ញុំក៏មិនមានអ្វីជំទាស់ដែរ។ សូមអរគុណ។

[១០:៥២:៥៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយកិច្ចពិភាក្សាលើសំណើសុំរបស់ក្រុមសហមេធាវីការពារក្ដី នួន ជា និងសហមេធាវីការពារក្ដី ខៀវ សំផន លើការស្នើសុំឲ្យអង្គជំនុំជម្រះទទួលយកឯកសារ អម្បាញ់មិញនេះ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

គឺបានចប់ហើយ។ ឥឡូវអង្គជំនុំជម្រះសូមថ្លែងអំណរគុណដល់ភាគីទាំងអស់ ដែលបានលើកឡើងនូវសារណាផ្ទាល់មាត់លើបញ្ហាដែលខាងលើដែលបានដាក់ឲ្យពិភាក្សានេះ ហើយជាមូលដ្ឋានសម្រាប់អង្គជំនុំជម្រះយកទៅពិនិត្យ ពិចារណា ពិភាក្សា ហើយនិងសម្រេចលើសំណើសុំឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។

ហើយសវនាការនៅព្រឹកនេះ ដល់ពេលសម្រាកហើយ។ ហើយអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើទៅបន្តធ្វើនៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃពុធសប្ដាហ៍នេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-893 ពាក់ព័ន្ធនឹងអង្គហេតុនៃការប្រព្រឹត្តចំពោះក្រុមមនុស្សជាគោលដៅជាក់លាក់ចំពោះជនជាតិចាម ដោយសារអង្គហេតុ ពាក់ព័ន្ធនឹងអង្គហេតុនេះ យើងនៅមានសាក្សីពីរបីរូប ចំនួនពីររូបដែលមិនទាន់បានស្ដាប់សក្ខីកម្មនៅឡើយ។ ហើយនេះជាឱកាសដែលយើងរៀបចំកាលវិភាគសវនាការទៅ យើងមានលទ្ធភាពក្នុងការស្ដាប់សក្ខីកម្មសាក្សីរូបនេះ។

ហើយក៏បញ្ជាក់ជម្រាបជូនភាគី និងសាធារណជនផងដែរ ថាសវនាការនៅថ្ងៃនេះ បានចប់នៅមុនពេលកំណត់ ដោយមូលហេតុសាក្សីដែលមានរហស្សនាម 2-TCW-880 ដែលអង្គជំនុំជម្រះបានគ្រោងស្ដាប់សក្ខីកម្មសាក្សីនៅ -- សក្ខីកម្មនៅថ្ងៃនេះ គាត់មានបញ្ហាសុខភាពធ្ងន់ធ្ងរដែលមិនអាចចូលរួមសវនាការបាន ហើយអង្គជំនុំជម្រះក៏មិនមានលទ្ធភាពក្នុងការរៀបចំកោះហៅសាក្សីផ្សេងទៀតមកជំនួសបាន។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបចូលរួមសវនាការវិញនៅថ្ងៃពុធ ទី០៩ ខែមីនា ឆ្នាំ២០១៦ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១០:៥៥ នាទី)*

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។